Public Disclosure Authorized

SFG2752 REV

# គម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅ អាស៊ីអាគ្នេយ៍ (SEA DRM) សម្រាប់កម្ពុជា

## ក្របខ័ណ្ឌរៀបចំផែនការជនជាតិដើមភាគតិច

Public Disclosure Authorized

*រៀបចំដោយ*

**អង្គភាពគ្រប់គ្រងគម្រោង**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ 7 មករា

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ខែធ្នូ ឆ្នាំ 2016**

កំណែទី 6

# មាតិកា


បញ្ជីតារាង ..................................................................................................................... i
ពាក្យបំព្រួញ ..................................................................................................................... ii
សេចក្តីថ្លែងអំណរគុណ ..................................................................................................... 1
1.0 **សេចក្តីផ្តើម** ............................................................................................................ 1
1.1 គោលបំណងអភិវឌ្ឍន៍នៃគម្រោង.................................................................................. 1
1.2 ទម្រង់ប្លង់ និងសមាសភាគដែលស្នើឡើង ........................................................................ 1
1.3 គោលនយោបាយការពារសុវត្ថិភាពដែលនៅជាធរមានរបស់ធនាគារពិភពលោក ................ 4
2.0 **ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដែលទាក់ទងនឹងជនជាតិដើមភាគតិច**............. 5
2.1 ច្បាប់កម្ពុជាដែលពាក់ព័ន្ធ............................................................................................ 5
2.1.1 រដ្ឋធម្មនុញ្ញកម្ពុជា (1993) ........................................................................................ 5
2.1.2 ច្បាប់ភូមិបាល (2001)................................................................................................ 5
2.2 លិខិតូបករណ៍អន្តរជាតិដែលពាក់ព័ន្ធ............................................................................ 6
3.0 **ជនជាតិដើមភាគតិចក្នុងតំបន់គម្រោង** ..................................................................... 6
4.0 **ផលប៉ះពាល់ ដែលអាចកើតចេញពីគម្រោង មកលើជនជាតិដើមភាគតិច** .......... 7
5.0 **ការចាត់ចែងអនុវត្តសម្រាប់ IPPF** .......................................................................... 8
5.1 ការជ្រើសរើសដោយផ្អែកលើវត្តមានជនជាតិដើមភាគតិច.............................................. 8
5.2 ការវាយតម្លៃហេតុប៉ះពាល់សង្គម .................................................................................. 9
5.3 ដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់................ 10
5.4 ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច.......................................................... 13
6.0 **ការចាត់ចែងតាមដាន និងវាយតម្លៃ** ........................................................................ 16
7.0 **យន្តការបណ្តឹងសារទុក្ខ**............................................................................................ 18
8.0 **ការចាត់ចែងបើកចំហសម្រាប់ IPDP ដែលត្រូវរៀបចំនៅក្រោម IPPF** ................ 20
9.0 **ឧបសម្ព័ន្ធ** ............................................................................................................... 20


# បញ្ជីតារាង


តារាងទី 1 ក្រុមជាតិពន្ធុនៅក្នុងទីតាំងអនុគម្រោង គិតតាមខេត្ត ........................................................ 6

# ពាក្យបំព្រួញ

| | | |
|---|---|---|
| **BP** | Bank Policy | គោលនយោបាយធនាគារពិភពលោក |
| **CERD** | International Convention on the Elimination of All Forms of Racial Discrimination | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងខាងជាតិសាសន៍ |
| **CSO** | Civil Society Organizations | អង្គការសង្គមស៊ីវិល |
| **DIA** | Designated Implementing Agencies | ទីភ្នាក់ងារអនុវត្ត |
| **DRFI** | Disaster Risk Financing and Insurance | ហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយនិងការធានារ៉ាប់រង |
| **DRM** | Disaster Risk Management | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ |
| **ESMF** | Environmental and Social Management Framework | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| **ESMP** | Environmental and Social Management Plan | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| **IAIA** | International Association for Impact Assessment | សមាគមអន្តរជាតិសម្រាប់ការវាយតម្លៃផលប៉ះពាល់ |
| **ICCPR** | International Convention on Civil and Political Rights | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនស៊ីវិលនិងនយោបាយ |
| **ICESCR** | International Convention on Economic, Social and Cultural Rights | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| **IDA** | International Development Association | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| **IP** | Indigenous Peoples | ជនជាតិដើមភាគតិច |
| **IPDP** | Indigenous Peoples Development Plan | ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច |
| **IPO** | Indigenous Peoples Organization | អង្គការជនជាតិដើមភាគតិច |
| **IPPF** | Indigenous Peoples Planning Framework | ក្របខ័ណ្ឌរៀបចំផែនការជនជាតិដើមភាគតិច |
| **IRC** | Inter-Ministerial Resettlement Committee | គណៈកម្មការអន្តរក្រសួងដោះស្រាយបញ្ហាតាំងទីលំនៅ |
| **MEF** | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MLMUPC** | Ministry of Land Management, Urban Planning, and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **MND** | Ministry of National Defence | ក្រសួងការពារជាតិ |
| **MOE** | Ministry of Environment | ក្រសួងបរិស្ថាន |
| **MPWT** | Ministry of Public Works and Transportation | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **MRD** | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **NGO** | Non-Government Organizations | អង្គការមិនមែនរដ្ឋាភិបាល |
| **OP** | Operational Policy | គោលនយោបាយប្រតិបត្តិ |
| **PAD** | Project Appraisal Document | ឯកសារវាយតម្លៃគម្រោង |
| **PAH** | Project Affected Households | គ្រួសាររងគ្រោះដោយសារគម្រោង |
| **PAP** | Resettlement Action Plan | ផែនការសកម្មភាពតាំងទីលំនៅឡើងវិញ |
| **PDRD** | Provincial Department of Rural Development | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| **PMO** | Project Management Office | ការិយាល័យគ្រប់គ្រងគម្រោង |
| **SEA DRM** | South East Asia Disaster Risk Management | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយតំបន់អាស៊ីអាគ្នេយ៍ |
| **SEO** | Social and Environmental Safeguard Office | ការិយាល័យការពារសុវត្ថិភាពបរិស្ថាន និងសង្គម |
| **SIA** | Social Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់សង្គម |

| | | |
|---|---|---|
| **SMMP** | Social Management and Monitoring Plan | ផែនការគ្រប់គ្រងនិងតាមដានសង្គម |
| **TA** | Technical Assistance | ជំនួយបច្ចេកទេស |
| **USD** | United State Dollar | ដុល្លាអាមេរិក |
| **WB** | World Bank | ធនាគារពិភពលោក |
| **WBG** | World Bank Group | ក្រុមធនាគារពិភពលោក |

# សេចក្ដីថ្លែងអំណរគុណ

របាយការណ៍ការពារសុវត្ថិភាពនេះត្រូវបានរៀបចំឡើង ជាផ្នែកមួយនៃសំណើគម្រោងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់តំបន់អាស៊ីអាគ្នេយ៍(SEA DRM) ដែលត្រូវផ្ដល់មូលនិធិគាំទ្រដោយក្រុមធនាគារពិភពលោក(WBG) តាមរយៈឥណទានពីសមាគមអភិវឌ្ឍន៍អន្តរជាតិនៅកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ របាយការណ៍នេះត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទនៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការណែនាំដោយលោក ប៉ម ជ្រាយ ប្រធានគម្រោង និងជាប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ លោក ទាង ឆាយហ៊ាង នាយកគម្រោង និងជាប្រធានការិយាល័យផែនការ នៃនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ។ លោក Jim Hamilton, លោក Jim Webb, បណ្ឌិត ដោក ដូម៉ា លោកស្រី សេង បុប្ផា លោកស្រី Derin Henderson, និងលោក Grant Bruce នៃក្រុមហ៊ុនទីប្រឹក្សា ហាត ហៀលប្រចាំតំបន់មេគង្គ ជាអ្នកផ្ដល់ជំនួយបច្ចេកទេស និងការគាំទ្រដល់ក្រសួងអភិវឌ្ឍន៍ជនបទ។

អ្នកនិពន្ធ សូមថ្លែងអំណរគុណចំពោះក្រុមធនាគារពិភពលោក ដែលបានផ្ដល់ការគាំទ្រ ជាពិសេស បណ្ឌិតHenrike Brecht ប្រធានក្រុម លោក ប៊ុន វាសនា មន្ត្រីប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ លោក ទេព ម៉ាកាជី អ្នកឯកទេសការពារសុវត្ថិភាពបរិស្ថាន និងលោក Sybounheung Phananouvong អ្នកឯកទេសការពារសុវត្ថិភាពសង្គម។ ក្រុមអ្នក និពន្ធសូមថ្លែងអំណរគុណផងដែរចំពោះមន្ត្រីរាជរដ្ឋាភិបាលកម្ពុជានៅការិយាល័យអភិបាលស្រុក ការិយាល័យនានានៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត នៅខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ដែលបានចំណាយពេលសម្រាប់ការពិគ្រោះយោបល់ និងតំណាងពីភូមិនានានៅក្នុងឃុំមៀន និងឃុំការពោធិ៍ប្រាំ ខេត្តត្បូងឃ្មុំ ឃុំកោះខ្នែរ ខេត្តក្រចេះ និងមកពីសហគមន៍ជនជាតិដើមភាគតិចនៅភូមិកំពង់ព្នៅ ខេត្តក្រចេះ ដែលបានផ្ដល់យោបល់និងចម្លើយតបនានា អំពីផលប៉ះពាល់ដែលអាចកើតមានបណ្ដាលពីអនុគម្រោងដែលបានស្នើឡើងទាំងនេះ។

## 1.0 សេចក្តីផ្តើម

ឯកសារនេះគឺជាក្របខ័ណ្ឌរៀបចំផែនការជនជាតិដើមភាគតិច(IPPF) សម្រាប់គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍ដែលស្នើឡើង (គម្រោង SEA DRM) ដែលរៀបចំឡើងជាមួយក្រសួងអភិវឌ្ឍន៍ជនបទ (MRD) សម្រាប់លទ្ធភាពទទួលហិរញ្ញប្បទានពីធនាគារពិភពលោក (WB)។

## 1.1 គោលបំណងអភិវឌ្ឍន៍នៃគម្រោង

សំណើគម្រោង SEA DRM ដែលទទួលមូលនិធិពីធនាគារពិភពលោក តាមរយៈសំណើឥណទានពី IDA ចំនួន 60 លានដុល្លារអាមេរិក និងអនុវត្តដោយរដ្ឋាភិបាលកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា មានគោលដៅកាត់បន្ថយហានិភ័យ និងពង្រីកសមត្ថភាពហិរញ្ញប្បទានសម្រាប់ហានិភ័យគ្រោះមហន្តរាយនៅអាស៊ីអាគ្នេយ៍ ក្នុងតំបន់ទន្លេមេគង្គក្រោម។

គម្រោងSEA DRM ត្រូវបានរំពឹងថា ជាការចាប់ផ្តើមពាក់ព័ន្ធរយៈពេលវែងមួយនៅថ្នាក់តំបន់ លើភាពធន់នឹងគ្រោះមហន្តរាយ និងអាកាសធាតុ។ នៅថ្នាក់តំបន់ គោលបំណងគឺលើកកំពស់ និងធ្វើសុខដុមូនីយកម្មការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ គោលបំណងនេះមានជាអាទិ៍៖ (i) សម្រួលឲ្យមានវិធានឆ្លងដែនសម្រាប់ការគ្រប់គ្រងទីជម្រាល និងការគ្រប់គ្រងគ្រោះមហន្តរាយ និងហានិភ័យអាកាសធាតុ (ii) ពង្រឹង និងធ្វើឲ្យស៊ីជម្រៅ ភាពធន់នៃច្រករបៀងពាណិជ្ជកម្មសេដ្ឋកិច្ចនៅថ្នាក់តំបន់ (iii) បង្កើតវិធីសាស្រ្តកម្រិតតំបន់សម្រាប់ការព្យាករណ៍ជលសាស្រ្ត-ឧតុនិយម និងការផ្តល់ ព័ត៌មានជាមុន (iv) លើកកំពស់វិធីសាស្រ្តថ្នាក់តំបន់សម្រាប់ហិរញ្ញប្បទាន និងការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ (DRFI) ដែលរួមទាំង ការប្រមូលផ្តុំហានិភ័យដែលអាចកើតមាន តាមរយៈយន្តការការពារហិរញ្ញវត្ថុរួម ប្រសិនបើយន្តការនេះត្រូវបានរកឃើញថាមានប្រសិទ្ធភាពលើការចំណាយ និងអានអនុវត្តបានដោយឈរលើហេតុផលនយោបាយ និង (v) ពង្រឹងប្រព័ន្ធព័ត៌មាន និងកម្រងទិន្នន័យបន្សុីគ្នានៅថ្នាក់តំបន់។

## 1.2 ទម្រង់ប្លង់ និងសមាសភាគដែលស្នើឡើង

គម្រោង SEA DRM ដែលស្នើឡើង មានបំណងគ្របដណ្តប់ការវិនិយោគលើការគ្រប់គ្រងហានិភ័យសំខាន់ៗនៃគ្រោះមហន្តរាយទឹកជំនន់ ដែលរួមចំណែកក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ និងកាត់បន្ថយភាពក្រីក្រ ព្រមទាំងពង្រឹងសមត្ថភាពនៅមូលដ្ឋាន ដើម្បីគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់រយៈពេលវែង នៅក្នុងប្រទេសឡាវ មីយ៉ាន់ម៉ា និងកម្ពុជា។ វិសាលភាពនៃការវិនិយោគនៅថ្នាក់ជាតិ និងថ្នាក់តំបន់ នឹងត្រូវកែសម្រួល នៅក្នុងអំឡុងពេលរៀបចំគម្រោង និងការរៀបចំផែនការសហគមន៍។ ជាលទ្ធផលគម្រោងនេះនឹងគ្របដណ្តប់ប្រទេសទាំងបីដែលបានស្នើឡើង ទោះបីតំបន់ដែលងាយរងគ្រោះមហន្តរាយជាងគេនៅក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា គឺជាគោលដៅសម្រាប់ការវិនិយោគជាក់លាក់ ហើយវិសាលភាពជាក់ស្តែងនឹងត្រូវកែសម្រួល នៅក្នុងអំឡុងពេលនៃការរៀបចំគម្រោងក៏ដោយ។ សកម្មភាពដូចខាងក្រោមនេះត្រូវបានគ្រោងនៅក្រោមគម្រោងនេះ៖

## *សមាសភាគ 1: ការវិនិយោគលើការគ្រប់គ្រងហានិភ័យទឹកជំនន់*

*សមាសភាគរង1.1. ការស្តារ និងកែលម្អផ្លូវលំជនបទដើម្បីបង្កើនភាពធន់៖* សមាសភាគនេះនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់ការស្តារ និងថែទាំដើម្បីបង្កើនភាពធន់ផ្លូវលំជនបទប្រវែងប្រមាណ 250 គ.ម ដែលរងការខូចខាតជាញឹកញាប់ ដោយសារព្រឹត្តិការណ៍ទឹកជំនន់ក្នុងពេលថ្មីៗនេះ ។ រចនាបថវិស្វកម្មសមស្រប លូដោះទឹកគ្រប់គ្រាន់ និងវិធីសាស្ត្របៃតង នឹងត្រូវប្រើប្រាស់ ដើម្បីបង្កើនភាពធន់នៃរចនាសម្ព័ន្ធផ្លូវលំទាំងនេះ។ ក្នុងករណីសមស្រប វិធីដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ក៏នឹងត្រូវយកមកអនុវត្តផងដែរ។ ការងារទាំងនេះនឹងត្រូវបំពេញបន្ថែមដោយវិធានការសុវត្ថិភាពចរាចរនៅតាមកន្លែងជិតសហគមន៍ និងសាលារៀន ដោយផ្អែកលើកម្មវិធីភូមិសុវត្ថិភាព ដែលរួមផ្សំសុវត្ថិភាពតាមដងផ្លូវ ជាមួយការគ្រប់គ្រង និងការរៀបចំផែនការហានិភ័យគ្រោះមហន្តរាយដោយសហគមន៍។ កាលានុវត្តិភាពនានានឹងត្រូវដាក់បញ្ចូល ដើម្បីប្រើប្រាស់បណ្តាញផ្លូវលំជនបទដើម្បីពង្រឹងវិធានការត្រួតពិនិត្យទឹក ដូចជា តាមរយៈការបង្កើនកំពស់ផ្លូវថ្នល់ ដើម្បីអាចដំណើរការជាទំនប់ការពារទឹកជំនន់ ឬការបំពាក់ទ្វារទឹកនៅតាមកន្លែងខ្លះៗដែលតភ្ជាប់ផ្លូវលំដែលលើកខ្ពស់ជាងមុន ដើម្បីត្រួតពិនិត្យលំហូរទឹកនៅរដូវប្រាំងនិងរដូវវស្សា។ លក្ខណៈវិនិច្ឆ័យដែលប្រើប្រាស់នៅក្នុងសម្រាប់ចាត់អាទិភាពផ្លូវលំជនបទសម្រាប់ការកែលម្អនៅក្រោមគម្រោងនេះ ផ្តោតលើផ្លូវលំនានាដែលបានជន់លិចជាញឹកញាប់និងបង្កើនការវិនិយោគដើម្បីស្តារ និងការកែលម្អភាពធន់នៃផ្លូវលំ។

*សមាសភាគរង 1.2. ការពង្រឹងស្ថាប័ន៖* សមាសភាគរងនេះនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់ការពង្រឹងស្ថាប័ននៅក្នុង វិស័យផ្លូវលំជនបទ។ ដោយឡែកសមាសភាគនេះនឹង (i)បង្កើតនិងប្រកាន់យកវិធីរៀបចំផែនការរចនាបថនិងស្តង់ដារសាងសង់ផ្លូវថ្នល់ដែលធន់ (ii)គាំទ្រដល់ការត្រួតពិនិត្យគុណភាព តាមរយៈមន្ទីរពិសោធន៍នៅនឹងកន្លែង និង (iii)កែលម្អសារពើភណ្ឌផ្លូវលំជនបទ។

## *សមាសភាគ 2: ការផ្តល់ហិរញ្ញប្បទាន និងការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ*

សមាសភាគនេះមានបំណងបង្កើនភាពធន់ខាងហិរញ្ញវត្ថុសម្រាប់កម្ពុជា នៅចំពោះមុខគ្រោះមហន្តរាយធម្មជាតិ និងសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីបំពេញតម្រូវការមូលនិធិសម្រាប់ដំណាក់កាលក្រោយគ្រោះមហន្តរាយ។ សមាសភាគនេះនឹងត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

*សមាសភាគរង 2.1៖* គាំទ្រដល់ការពង្រឹងភាពធន់ខាងហិរញ្ញវត្ថុរបស់ជាតិ (0,5លានដុល្លាអាមេរិក ជាជំនួយឥតសំណងបានពីមូលនិធិត្រឹះ)៖ សមាសភាគរងនេះនឹងកសាងសមត្ថភាពខាងហិរញ្ញវត្ថុសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្លើយតបនឹងហានិភ័យគ្រោះមហន្តរាយ គាំទ្រដល់ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រជាតិហិរញ្ញវត្ថុសម្រាប់ហានិភ័យគ្រោះមហន្តរាយ និងសម្រួលដល់ការចូលរួមរបស់កម្ពុជា ក្នុងការរៀបចំនិងការបង្កើតមូលនិធិធានារ៉ាប់រងភាពធន់នឹងគ្រោះមហន្តរាយនៅអាស៊ីគ្នេយ៍(SEADRIF) ដែលជាយន្តការប្រមូលផ្តុំហានិភ័យគ្រោះមហន្តរាយថ្នាក់តំបន់ ដែលបានបង្កើតឡើងដើម្បីផ្តល់ឲ្យប្រទេសដែលចូលរួម នូវហិរញ្ញប្បទានសម្រាប់ការឆ្លើយតបបានឆាប់រហ័សនិងប្រកបដោយប្រសិទ្ធភាព ដោយតម្លៃសមស្រប សម្រាប់ដំណាក់កាលក្រោយគ្រោះមហន្តរាយ។ សមាសភាគរងនេះនឹងត្រូវទទួលហិរញ្ញវត្ថុតាមរយៈជំនួយឥតសំណងពីមូលនិធិត្រឹះ។

*សមាសភាគរង 2.2៖ ការបង់ថ្លៃសម្រាប់ការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ (10 លានដុល្លាអាមេរិក ពីឥណទានរបស់IDA)៖* សមាសភាគរងនេះនឹងជួយរដ្ឋាភិបាលដើម្បីមានលទ្ធភាពប្រើប្រាស់ការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយដោយឡែកមួយ ដោយផ្តល់ហិរញ្ញប្បទានសម្រាប់ថ្លៃធានារ៉ាប់រងសម្រាប់រយៈពេលបីឆ្នាំដល់មូលនិធិធានារ៉ាប់រងហានិភ័យអន្តរជាតិ ដូចជា SEADRIF ដែលបានបង្កើតឡើងថ្មីៗនេះ ឬតាមរយៈគនាគាររបស់ធនាគារពិភពលោក។ មានការលើកស្នើផងដែរឲ្យរៀបចំសមាសភាគនេះតាមវិធីមួយដែលប្រសិនបើមូលនិធិ SEADRIF នៅពុំទាន់អាចដំណើរការបានរហូតដល់ពេលត្រួតពិនិត្យនៅពាក់កណ្តាលគម្រោងនេះ មូលនិធិសម្រាប់សមាសភាគរងនេះ នឹងត្រូវបង្វែរទៅសមាសភាគ 1។

*សមាសភាគរង 2.3៖ ការគាំទ្រដល់ការពង្រឹងភាពធន់នឹងគ្រោះមហន្តរាយ (0,5លានដុល្លាអាមេរិកជាជំនួយឥតសំណងពីមូលនិធិត្រឹះ)៖* សមាសភាគរងនេះនឹងកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ជ្រាបជាលក្ខណៈប្រព័ន្ធនូវភាពធន់នឹងគ្រោះមហន្តរាយ និងអាកាសធាតុ ទៅក្នុងដំណើរការរៀបចំផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍ ដោយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធដទៃទៀត និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

## *សមាសភាគ 3: ការគ្រប់គ្រងគម្រោង*

សមាសភាគនេះមានបំណងគាំទ្រដល់ការអនុវត្តការងារប្រចាំថ្ងៃនៃគម្រោងនេះ។ សមាសភាគនេះនឹងផ្តល់ហិរញ្ញវត្ថុសម្រាប់ការគាំទ្រដល់ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពសម្រាប់គ្រប់គ្រងគម្រោង ការសម្របសម្រួល លទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ទិដ្ឋភាពបច្ចេកទេសនិងកិច្ចការពារសុវត្ថិភាព ការតាមដាននិងវាយតម្លៃ (M&E) និងការធ្វើរបាយការណ៍។

## *សមាសភាគ 4: សមាសភាគឆ្លើយតបនឹងគ្រោះអាសន្នជាយថាហេតុ*

សមាសភាគនេះនឹងអនុញ្ញាតឲ្យមានការវិភាជន៍ឡើងវិញ នូវផលចំណូលជាឥណទានពីសមាសភាគដទៃទៀតដើម្បីផ្តល់ការគាំទ្រដល់ការស្តារឡើងវិញនូវស្ថានភាពអាសន្ន និងការសាងសង់ឡើងវិញ បន្ទាប់ពីវិបត្តិ ឬគ្រោះអាសន្ន ស្របតាមលក្ខណៈវិនិច្ឆ័យ។ ឯកសារណែនាំប្រតិបត្តិការឆ្លើយតបនឹងគ្រោះអាសន្ន នឹងត្រូវរៀបចំឡើងនៅក្នុងអំឡុងពេលនៃការអនុវត្តអនុគម្រោង សម្រាប់គ្រោះមហន្តរាយដែលស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលហិរញ្ញវត្ថុគាំទ្រ ដោយចែងពិស្តារអំពីការគាំទ្រហិរញ្ញវត្ថុ លទ្ធកម្ម កិច្ចការពារសុវត្ថិភាព និងការចាត់ចែងអនុវត្តដទៃទៀតដែលចាំបាច់។

គោលការណ៍ណែនាំសម្រាប់នីតិវិធីរបស់ធនាគារពិភពលោក ក្នុងការឆ្លើយតបបន្ទាន់ទៅនឹងវិបត្តិ និងស្ថានភាពអាសន្ន ចែងថា៖ "ការធានាឲ្យមានកិច្ចប្រឹងប្រែងក្នុងការគ្រប់គ្រងហានិភ័យដែលអាចកើតឡើង ទន្ទឹមនឹងទទួលស្គាល់អំពីសារៈសំខាន់នៃប្រតិបត្តិការដែលបានស្នើឡើងសម្រាប់ស្ថានភាពអាសន្ន និងតម្រូវការដើម្បីផ្តល់ជំនួយបន្ទាន់ នៅតែជាគោលបំណងបឋមនៃវិធីសាស្ត្ររបស់ធនាគារពិភពលោក សម្រាប់គ្រប់គ្រងកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម នៅក្នុងករណីអាសន្ន។ ស្របជាមួយគោលបំណងនេះ និងដើម្បីសម្រួលឲ្យមានការឆ្លើយតបឆាប់រហ័ស ក្រុមការងារជំពូកកិច្ចនានា ត្រូវធ្វើការអនុម័ត ដូចក្នុងករណីលទ្ធកម្មផងដែរនូវគោលការណ៍នៃការធ្វើប្រតិភូកម្មកាន់តែច្រើនជាងមុនឲ្យបានឆាប់រហ័ស ដោយងាយស្រួល និងជាមួយភាពបត់បែនបាន ក្នុងការអនុវត្តគោលនយោបាយការពារសុវត្ថិភាពដែលពាក់ព័ន្ធ។"

## 1.3 គោលនយោបាយការពារសុវត្ថិភាពដែលនៅជាធរមានរបស់ធនាគារពិភពលោក

នៅក្រោមគម្រោង SEA DRM សម្រាប់កម្ពុជា តំបន់ងាយប្រឈមគ្រោះមហន្តរាយ នឹងក្លាយជាគោលដៅនៃការវិនិយោគជាក់លាក់។ ផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានរំពឹងថានឹងកើតមាននៅកម្រិតខុសៗគ្នា និងក្នុងទំហំខុសគ្នា បណ្តាលពីការអនុវត្តអនុគម្រោងនានា ដោយអាស្រ័យលើទំហំ និងទីតាំងនៃអនុគម្រោងទាំងនោះ ដែលនៅត្រូវពិពណ៌នាឲ្យបានលំអិត នៅក្នុងការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។ ផ្អែកតាមការពិគ្រោះយោបល់ដំបូងជាមួយអ្នកទទួល ដែលទាក់ទងនឹងការវិនិយោគដែលអាចកើតមាន គម្រោងនេះទំនងជានឹងត្រូវអនុវត្តនូវគោលនយោបាយការពារសុវត្ថិភាពរបស់ធនាគារពិភពលោក៖ *ជនជាតិដើមភាគតិច* (OP/BP 4.10) និង *ការតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្ត* (OP/BP 4.12), ក៏ដូចជា គោលនយោបាយការពារសុវត្ថិភាពបរិស្ថានចំនួនបីខាងក្រោមនេះផងដែរគឺ *ការវាយតម្លៃបរិស្ថាន* (OP/BP 4.01), *ទីជម្រកធម្មជាតិ* (OP/BP 4.04), *ធនធានវប្បធម៌រូបិយ៍* (OP/BP 4.11)។

គោលនយោបាយការពារសុវត្ថិភាពជនជាតិដើមភាគតិច (OP 4.10) នឹងត្រូវអនុវត្តចំពោះគម្រោងនេះ ដោយសារជនជាតិភាគតិច អាចរងការប៉ះពាល់ដោយផ្ទាល់ ឬ ប្រយោល ដូច្នេះគឺជាកម្មវត្ថុនៃលក្ខណៈវិនិច្ឆ័យ OP/BP 4.10។

គោលនយោបាយនេះទទួលស្គាល់ថា អត្តសញ្ញាណ និងវប្បធម៌ដោយឡែករបស់ជនជាតិដើមភាគតិច នៅតែមានចំណងទាក់ទងស្មុគស្មាញជាមួយដីធ្លី ដែលជាកន្លែងពួកគេរស់នៅ និងធនធានធម្មជាតិដែលជាបង្អែកសម្រាប់ការរស់នៅរបស់ពួកគេ។ OP/BP 4.10 ត្រូវបានរៀបចំឡើង ដើម្បីធានាថា គម្រោងដែលទទួលហិរញ្ញវត្ថុពីធនាគារពិភពលោក នឹងមិនបង្កផលប៉ះពាល់អវិជ្ជមានចំពោះជនជាតិដើមភាគតិច និងជនជាតិភាគតិចឡើយ ឬ នៅពេលមិនអាចបញ្ចៀសបាន ត្រូវកាត់បន្ថយ បន្ធូរបន្ថយ និង/ឬ ផ្តល់សំណង សម្រាប់ផលប៉ះពាល់បែបនោះ។ គោលនយោបាយនេះមានគោលដៅលើកកំពស់ផលប្រយោជន៍ពីការអភិវឌ្ឍដោយចីរភាព និងឱកាសសម្រាប់ជនជាតិដើមភាគតិច ដែលអាចទទួលផលបាន សមស្របតាមប្រពៃណី និងជាបរិយាប័ន្ន។ OP/BP 4.10 បង្កើតលក្ខខណ្ឌនៃប្រតិបត្តិការ៖ ការជ្រើសរើស ការវាយតម្លៃសង្គម ការពិគ្រោះយោបល់ជាមួយសហគមន៍ដែលពាក់ព័ន្ធ ការរៀបចំផែនការ ឬក្របខ័ណ្ឌ និងការបើកចំហព័ត៌មាន។ គោលនយោបាយនេះ ក៏តម្រូវឲ្យប្រទេសដែលទទួលឥណទាន ស្វែងរកការគាំទ្រទូលំទូលាយពីសហគមន៍ជនជាតិដើមភាគតិចផងដែរ តាមរយៈដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ មុននឹងសម្រេចរៀបចំគម្រោងណាមួយដែលផ្តោតលើ ឬដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច និងត្រូវរក្សាទំនាក់ទំនងដែលមានជាប្រចាំក្នុងរយៈពេលកន្លងមក ដោយផ្អែកលើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ជាមួយជនជាតិដើមភាគតិច ដែលរងការប៉ះពាល់ពីគម្រោងណាមួយ នៅទូទាំងអាយុកាលនៃគម្រោង។ នៅទីបំផុត OP/BP 4.10 ព្យាយាមទទួលស្គាល់ គោរព និង ថែរក្សាវប្បធម៌ ចំណេះដឹង និងប្រពៃណីរបស់ជនជាតិដើមភាគតិច និងផ្តល់ឲ្យពួកគេនូវឱកាស ដើម្បីបន្សុំាទៅនឹងលក្ខខណ្ឌប្រែប្រួល តាមរូបភាព និងក្នុងរយៈពេល ដែលពួកគេអាចទទួលយកបាន។

OP/BP 4.10 មិនផ្តល់និយមន័យអំពីពាក្យ "ជនជាតិដើមភាគតិច"ឡើយ ដោយសារពុំមាននិយមន័យដែលមានការទទួលស្គាល់ជាសកលឡើយ។ សម្រាប់គោលបំណងនៃគោលនយោបាយនេះ ពាក្យថា"ជន

ជាតិដើមភាគតិច”ត្រូវបានប្រើប្រាស់ក្នុងន័យទូទៅ ដោយសំដៅលើក្រុមជនដែលបង្ហាញពីអត្តសញ្ញាណវប្បធម៌ និងសង្គមដាច់ដោយឡែកនិងដែលងាយរងគ្រោះ ដោយបង្ហាញឲ្យឃើញពីសំណុំលក្ខណៈខុសៗគ្នាដូចតទៅ៖

ក) កំណត់អត្តសញ្ញាណខ្លួនឯង ថាជាសមាជិកនៃក្រុមដែលមានវប្បធម៌ដាច់ដោយឡែក ដែលមានដើមកំណើតនៅក្នុងកន្លែងនោះ ហើយអត្តសញ្ញាណនេះត្រូវបានទទួលស្គាល់ដោយអ្នកដទៃ

ខ) ការផ្សារភ្ជាប់រួមគ្នាជាសមូហភាពទៅនឹងទីជម្រកភូមិសាស្ត្រដាច់ដោយឡែក ឬ ដែនដីពីដូនតា នៅក្នុងទីតាំងគម្រោង និង ទៅនឹងធនធានធម្មជាតិ នៅក្នុងទីជម្រកនិងដែនដីទាំងនោះ

គ) ស្ថាប័នវប្បធម៌ប្រពៃណី សេដ្ឋកិច្ច សង្គម ឬ នយោបាយ ដែលមានលក្ខណៈដាច់ចេញពីអ្វីដែលមាននៅក្នុងសង្គមនៃមនុស្សភាគច្រើន និង

ឃ)ភាសាកំណើតមួយ ដែលជាញឹកញាប់មានភាពខុសប្លែកពីភាសាផ្លូវការនៃប្រទេស ឬ តំបន់នោះ។

OP/BP 4.10 ក៏ត្រូវអនុវត្តចំពោះសហគមន៍ ឬ ក្រុមជនជាតិដើមនានា ដែលនៅក្នុងអំឡុងពេលមួយជីវិតរបស់សមាជិកនៃសហគមន៍ ឬ ក្រុមនេះ បានបាត់បង់ភាពជិតស្និទ្ធជាសមូហភាពទៅនឹងទីជម្រក ឬ ដែនដីដូនតាដោយឡែករបស់ខ្លួន នៅក្នុងតំបន់គម្រោង ដោយសារតែការបែកចេញពីគ្នាដោយបង្ខំ ជម្លោះ កម្មវិធីតាំងទីលំនៅឡើងវិញរបស់រដ្ឋាភិបាល ការបាត់បង់សិទ្ធិចំពោះដីធ្លី គ្រោះមហន្តរាយធម្មជាតិ ឬ ការដាក់បញ្ចូលដែនដីបែបនោះទៅក្នុងទីក្រុងណាមួយ។ គោលនយោបាយនេះក៏អនុវត្តផងដែរចំពោះអ្នករស់នៅក្នុងព្រៃ អ្នកបរបាញ់និងប្រមូលផល គង្វាលសត្វ ឬ ក្រុមពនេចរដទៃទៀត ដែលអាស្រ័យលើភាពស្របគ្នាជាមួយលក្ខណៈវិនិច្ឆ័យនៃការពិចារណាពិសេសនៅក្នុងវាក្យខ័ណ្ឌ 16 នៃគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច (OP/BP 4.10)។

# 2.0 ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដែលទាក់ទងនឹងជនជាតិដើមភាគតិច

## 2.1 ច្បាប់កម្ពុជាដែលពាក់ព័ន្ធ

### 2.1.1 រដ្ឋធម្មនុញ្ញកម្ពុជា (1993)

រដ្ឋធម្មនុញ្ញកម្ពុជា (1993) ធានាសិទ្ធិដូចគ្នាសម្រាប់ពលរដ្ឋខ្មែរគ្រប់រូប ដោយមិនប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ភាសា និងជំនឿសាសនាឡើយ។ នៅក្នុងវេទិកានយោបាយសម្រាប់នីតិកាលទីបីនៃសភាជាតិ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ផងដែរនូវសារៈសំខាន់នៃសង្គមកម្ពុជាដែលមានប្រពៃណីចម្រុះ ។

មាត្រា 31 ចែងថា ពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ។

### 2.1.2 ច្បាប់ភូមិបាល (2001)

ច្បាប់ភូមិបាលកម្ពុជា (2001) ផ្តល់សិទ្ធិចំពោះកម្មសិទ្ធដីជាសមូហភាពដល់សហគមន៍ជនជាតិដើម។ មាត្រា 25 ចែងថា កម្មសិទ្ធិនៃអចលនវត្ថុ ត្រូវបានរដ្ឋផ្តល់ឲ្យជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាព។ កម្ម

សិទ្ធិសម្ហហភាព រួមមាន រាល់សិទ្ធិ និងការការពារកម្មសិទ្ធិ ដូចកម្មសិទ្ធិឯកជនដែរ។ ការអនុវត្តសិទ្ធិលើកម្ម សិទ្ធិសម្ហហភាព ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឲ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅ ដែលទាក់ទងនឹងអចលនវត្ថុ ដូចជាច្បាប់ការពារបរិស្ថានជាដើម ( មាត្រា 26)។

ក្នុងមាត្រា 23 សហគមន៍ជនជាតិដើមភាគតិច ត្រូវបានឲ្យនិយមន័យថាជា "ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពគ្នានៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅទៅតាមប្រពៃណី និងការដាំដុះលើលើដី ដែលខ្លួនកាន់កាប់ ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសម្ហហភាព។"

## 2.2 លិខិតូបករណ៍អន្តរជាតិដែលពាក់ព័ន្ធ

កម្ពុជាគឺជាហត្ថលេខីនៃលិខិតូបករណ៍អន្តរជាតិមួយចំនួន ដែលការពារសិទ្ធិជនជាតិដើមភាគតិច។ បរិជាននេះមានជាអាទិ៍ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR), អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនស៊ីវិល និងសិទ្ធិនយោបាយ(ICCPR) និងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រកាន់ពូជសាសន៍(CERD)។ កម្ពុជាក៏ជាហត្ថលេខីនៃអនុសញ្ញាស្តីពីជីវៈចម្រុះផងដែរ(1992) ដែលទទួលស្គាល់ពីតួនាទីរបស់ជនជាតិដើមភាគតិច ក្នុងកិច្ចការពារជីវៈចម្រុះ។

# 3.0 ជនជាតិដើមភាគតិចក្នុងតំបន់គម្រោង

កម្ពុជា ពុំមានព័ត៌មានដែលអាចទុកចិត្តបានអំពីប្រជាសាស្ត្រ និងជាតិពន្ធុសាស្ត្រឡើយ ដោយសារតែប្រវត្តិនា ពេលថ្មីៗនេះនៃរបបប្រល័យពូជសាសន៍ សង្គ្រាម ចំណាកស្រុកជាទ្រង់ទ្រាយធំ និងការតាំងទីលំនៅឡើងវិញដោយបង្ខំ។ ជម្រឿនប្រជាជនកម្ពុជាឆ្នាំ 1998 បានបង្ហាញពីជនជាតិដើមភាគតិចចំនួន 17 ក្រុមខុសៗគ្នា ហើយតារាងទី 1 ផ្តល់សេចក្តីសង្ខេបអំពីក្រុមជនជាតិ នៅក្នុងខេត្តទាំងប្រាំមួយដែលមានអនុគម្រោង។ ផ្អែកតាមភាសានិយាយ ជម្រឿននេះបានប៉ាន់ស្មានថា ចំនួនជនជាតិដើមភាគតិចមានប្រមាណ 101.000 នាក់ ឬត្រូវជា 0,9% នៃចំនួនប្រជាជនសរុបក្នុងពេលនោះ ដែលមាន 11,4 លាននាក់។ ទោះជាយ៉ាងណាក៏ដោយការស្រាវជ្រាវជាក់ស្តែងបង្ហាញថា តួលេខនេះទំនងបំផុតជាទាបជាងតួលេខពិតប្រាកដ ដែលអាចមានដល់ 190.000 នាក់ ឬ 1,4% នៃចំនួនប្រជាជនកម្ពុជាសរុប។

**តារាងទី 1 ក្រុមជាតិពន្ធុនៅក្នុងទីតាំងអនុគម្រោង គិតតាមខេត្ត**

| ក្រុមជនជាតិ | ខេត្ត | | | | | |
|---|---|---|---|---|---|---|
| | ស្ទឹងត្រែង | ក្រចេះ | កំពង់ចាម | សៀមរាប | កណ្តាល | ត្បូងឃ្មុំ |
| ខ្មែរ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ឡាវ | ✓ | - | - | ✓ | - | - |
| កាវ៉ែត | ✓ | - | - | - | - | - |
| កួយ | ✓ | ✓ | - | - | - | - |
| វៀតណាម | ✓ | ✓ | ✓ | ✓ | ✓ | - |
| ចិន | ✓ | - | ✓ | ✓ | - | - |

| | | | | | | |
|---|---|---|---|---|---|---|
| ព្នង | ✓ | ✓ | - | - | - | - |
| លុន | ✓ | - | - | - | - | - |
| ប៊ុនណង | - | ✓ | - | - | - | - |
| មិល | - | ✓ | - | - | - | - |
| ខុញ | - | ✓ | - | - | - | - |
| ក្រោល | - | ✓ | - | - | - | - |
| ស្ទាង | - | ✓ | - | - | - | - |
| ស្មៀង | - | - | ✓ | - | - | - |
| តាមួន | - | ✓ | - | - | - | - |
| ប្រាវ | ✓ | - | - | - | - | - |
| គ្រឿន | ✓ | - | - | - | - | - |
| ចាម | ✓ | - | ✓ | ✓ | ✓ | - |
| សំរ៉ែ | - | - | - | ✓ | - | - |
| ទំពួន | ✓ | - | - | - | - | - |
| កាចក់ | ✓ | - | - | - | - | - |
| ចារ៉ាយ | ✓ | - | - | - | - | - |
| ថៃ | ✓ | - | - | - | - | - |

## 4.0 ផលប៉ះពាល់ ដែលអាចកើតចេញពីគម្រោង មកលើជនជាតិដើមភាគតិច

គម្រោង SEA DRM នៅកម្ពុជា មិនរំពឹងថាបង្កការប៉ះពាល់អវិជ្ជមានចំពោះជនជាតិដើមភាគតិច (IP) ឡើយ ដែលរួមទាំង ក្រុមជនជាតិភាគតិច។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់ផ្ទាល់អាចកើតឡើងពីការអនុវត្តអនុគម្រោង។ ឧទាហរណ៍ ការចល័ត និងភាពងាយប្រើប្រាស់សេវានានា គឺជាបញ្ហាមួយ ប្រសិនបើបណ្តាញផ្លូវលំនិងស្ពាន មានលក្ខណៈទ្រុឌទ្រោម។

ការទទួលបានសេវាថែទាំសុខភាពគឺជាអាទិភាពរបស់ IP ដោយសារឃុំនានារបស់ពួកគេ ស្ថិតនៅឆ្ងាយពីមន្ទីរពេទ្យស្រុក ឬ មណ្ឌលសុខភាព។ ការសិក្សារបស់កុមារ គឺជាអាទិភាពមួយសម្រាប់ IP ប៉ុន្តែយ៉ាងហោចណាស់ កុមារក្នុងអាយុចូលរៀននៅថ្នាក់បឋមសិក្សាចំនួន ជប់ភាគរយ មិនបានចូលរៀនឡើយ ឬមួយដោយសារសាលារៀននៅឆ្ងាយពីផ្ទះ ឬពេលវេលាដែលពួកគេត្រូវចំណាយដើម្បីមកកាន់សាលារៀន។ ក្រៅពីនេះ ក៏មានអត្រាខ្ពស់នៃការបោះបង់ចោលសាលាផងដែរ ដោយសារតែកត្តាមួយចំនួន ដែលរួមទាំង ពេលវេលា ដើម្បីធ្វើដំណើរមកសាលារៀន និង/ឬ ផ្លូវ និងស្ពានទ្រុឌទ្រោម។

ជនជាតិដើមភាគតិចមានកង្វល់អំពីការធ្វើអាជីវកម្មធនធានធម្មជាតិប្រសិនបើផ្លូវថ្នល់ត្រូវបានកែលម្អ។ ជនជាតិដើមភាគតិចបានចាត់ទុកការបាត់បង់ព្រៃឈើ ការជួញដូរ សត្វព្រៃ ការបាត់បង់សត្វព្រៃ និងផលនេសាទ គឺជាកង្វល់សំខាន់ខាងបរិស្ថាន។ ពួកគាត់យល់ថា ការបង្កើនការយល់ដឹង និងការបណ្តុះបណ្តាល អំពី

ការពង្រឹងការអនុវត្តច្បាប់ចំពោះការកាប់ឈើល្មើសច្បាប់ និងការជួញដូរសត្វព្រៃ គឺជាផ្នែកមួយនៃការងារអភិវឌ្ឍន៍របស់ឃុំ។

## 5.0 ការចាត់ចែងអនុវត្តសម្រាប់ IPPF

ការអនុវត្ត IPPF សម្រាប់អនុគម្រោងដែលទទួលការគាំទ្រមូលនិធិនៅក្នុងតំបន់នានាដែលមានជនជាតិដើមរស់នៅ ទាមទារឲ្យមាន (ក)ការជ្រើសរើសដោយធនាគារពិភពលោក ដើម្បីកំណត់ឲ្យឃើញថាតើមានជនជាតិដើមភាគតិចឬទេ ឬ មានការជាប់ជំពាក់ជាសមូហភាពទៅនឹងទីតាំងគម្រោងដែរឬទេ (ខ)ប្រទេសដែលជាអ្នកទទួលឥណទាន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់សង្គម ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់ដែលអាចមាន និងកំណត់អត្តសញ្ញាណអត្ថប្រយោជន៍សមស្របតាមប្រពៃណី (គ) ប្រទេសដែលទទួលឥណទាន ត្រូវចាត់ចែងការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ជាមួយជនជាតិភាគតិចដែលរងការប៉ះពាល់ ដែលនាំទៅរកការគាំទ្រទូលំទូលាយរបស់សហគមន៍ ចំពោះសកម្មភាពដែលពាក់ព័ន្ធនៅក្រោមគម្រោង និង (ឃ) ប្រទេសជាអ្នកទទួលឥណទានត្រូវរៀបចំ និងបើកចំហដល់ជនជាតិដើមភាគតិច នូវផែនការអភិវឌ្ឍន៍ជនជាតិដើម (ដើម្បីបំពេញបន្ថែមលើក្របខ័ណ្ឌរៀបចំផែនការជនជាតិដើមភាគតិច) ដើម្បីដោះស្រាយបញ្ហានានាដែលទាក់ទងនឹងជនជាតិភាគតិច ផ្តល់អត្ថប្រយោជន៍សមស្របតាមប្រពៃណី និងធានាឲ្យមានការបញ្ចៀស ឬ កាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។

កម្រិតពិស្តារចាំបាច់ដើម្បីសម្រេចតាមលក្ខខណ្ឌនៃការទទួលបានឥណទាន មានចែងក្នុងចំណុច (ខ), (គ), និង (ឃ) ខាងលើ ដែលមានកម្រិតសមាមាត្រទៅនឹងភាពស្មុគស្មាញនៃគម្រោងដែលស្នើឡើង និងស្របតាមប្រភេទ និងទំហំនៃផលប៉ះពាល់ដែលអាចកើតមាននៅក្រោមគម្រោងដែលស្នើឡើង មកលើជនជាតិដើមភាគតិច ទោះបីផលប៉ះពាល់នោះអវិជ្ជមាន ឬវិជ្ជមានក៏ដោយ។

## 5.1 ការជ្រើសរើសដោយផ្អែកលើវត្តមានជនជាតិដើមភាគតិច

ធនាគារពិភពលោកនឹងធ្វើការជ្រើសរើសតាំងពីដំបូង ក្នុងដំណាក់កាលរៀបចំគម្រោង ដើម្បីកំណត់ថាតើមានជនជាតិដើមភាគតិចក្នុងតំបន់គម្រោង ឬមានការជាប់ជំពាក់ជាសមូហភាពទៅនឹងតំបន់គម្រោងដែរឬទេ។ ធនាគារពិភពលោក អាចស្វែងរកការវិនិច្ឆ័យបច្ចេកទេសពីអ្នកវិទ្យាសាស្ត្រសង្គមដែលមានគុណវុឌ្ឍិ ជាមួយជំនាញអំពីក្រុមសង្គម និងវប្បធម៌នៅក្នុងតំបន់នេះ។ ធនាគារពិពលោក ក៏នឹងពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិចដែលពាក់ព័ន្ធ និងប្រទេសជាអ្នកទទួលឥណទានផងដែរ។ ធនាគារពិភពលោកអាចអនុវត្តតាមក្របខ័ណ្ឌរបស់ប្រទេសជាអ្នកទទួលឥណទានសម្រាប់ការកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច នៅក្នុងពេលជ្រើសរើសគម្រោង ក្នុងពេលដែលក្របខ័ណ្ឌនោះស្របគ្នាជាមួយគោលនយោបាយនេះ។

ផ្អែកតាមការជ្រើសរើសនេះ ប្រសិនបើធនាគារពិភពលោកយល់ឃើញថា មានជនជាតិដើមភាគតិច ឬមានការ ជាប់ជំពាក់ជាសមូហភាពទៅនឹងតំបន់គម្រោង គេត្រូវអនុវត្ត OP/BP 4.10 ហើយនីតិវិធីដូចមានអធិប្បាយក្នុង IPPF នេះនឹងត្រូវអនុវត្តតាម។ ប្រការនេះរាប់បញ្ចូលលក្ខខណ្ឌដែលប្រទេសជាអ្នកទទួលឥណទាន ត្រូវធ្វើការវាយតម្លៃផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានដែលអាចកើតមានបណ្តាលពីគម្រោង មកលើជនជាតិដើមភាគតិច និងដើម្បីពិនិត្យជម្រើសជំនួសសម្រាប់គម្រោង ដែលផលប៉ះពាល់អវិជ្ជមានអាចមានទំហំធំ។

## 5.2 ការវាយតម្លៃហេតុប៉ះពាល់សង្គម

ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) គឺជាដំណើរការនៃការកំណត់អត្តសញ្ញាណ និងការពិនិត្យឥទ្ធិពលសង្គម នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ឬដែលស្នើឡើង និងអន្តរាគមន៍អភិវឌ្ឍន៍ដទៃទៀត។ យោងតាមសមាគមអន្តរជាតិសម្រាប់ការវាយតម្លៃផលប៉ះពាល់ ប្រការនេះរាប់បញ្ចូល ដំណើរការនានានៃការវិភាគ ការតាមដាន និងគ្រប់គ្រងផលវិបាកខាងសង្គមដែលមានការគ្រោងទុកជាមុន និងដែលគ្មានការគ្រោងទុក ទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ឬ អន្តរាគមន៍ដែលគ្រោងទុក (គោលនយោបាយ កម្មវិធី ផែនការគម្រោង) និងដំណើរការប្រែប្រួលណាមួយនៃសង្គមដែលបង្កដោយអន្តរាគមន៍ទាំងនោះ។

ទំហំ កម្រិតស៊ីជម្រៅ និងប្រភេទនៃការវិភាគនៅក្នុងការវាយតម្លៃសង្គម មានកម្រិតសមាមាត្រទៅនឹងប្រភេទ និងវិសាលភាពនៃផលប៉ះពាល់ដែលអាចកើតចេញពីគម្រោងដែលស្នើឡើង មកលើជនជាតិដើមភាគតិច ទោះបីឥទ្ធិពលទាំងនោះវិជ្ជមាន ឬអវិជ្ជមានក៏ដោយ។ SIA គួរតែបានបញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម នៃអនុគម្រោង(ESMP) ដូចដែលបានអធិប្បាយនៅក្នុង ESMF ហើយលទ្ធផលនឹងត្រូវប្រើប្រាស់សម្រាប់រៀបចំផែនការតាមដាននិងគ្រប់គ្រងសង្គម (SMMP)។

ក្នុងករណីដែលដំណើរការជ្រើសរើស ដូចមានចែងក្នុងជំពូក 5.1 បានរកឃើញវត្តមានជនជាតិដើមភាគតិចក្នុងតំបន់គម្រោង និងអនុគម្រោង ដំណើរការនៃការវាយតម្លៃសង្គមដោយឡែកមួយនឹងត្រូវអនុវត្តស្របតាមគោលការណ៍ដូចមានចែងក្នុង OP 4.10។ ដំណើរការនេះត្រូវរាប់បញ្ចូលចំណុចនានាដូចតទៅ៖

(ក) អាស្រ័យលើទំហំនៃអនុគម្រោង ការពិនិត្យក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច នៅក្នុងសហគមន៍ដែលរងការប៉ះពាល់។

(ខ) ការប្រមូល និងវិភាគព័ត៌មានគោលនានាដែលពាក់ព័ន្ធអំពីសំណុំលក្ខណៈវប្បធម៌ សង្គមសេដ្ឋកិច្ច និងនយោបាយនៃសហគមន៍ជនជាតិដើមដែលរងការប៉ះពាល់ និងប្រសិនបើពាក់ព័ន្ធ ក៏ត្រូវប្រមូលព័ត៌មានអំពីដីធ្លី និងដែនដី ដែលពួកគេធ្លាប់កាន់កាប់តាមប្រពៃណី និងធនធានធម្មជាតិដែលជាបង្អែកសម្រាប់ពួកគេផងដែរ។

(គ) ការប្រើប្រាស់ព័ត៌មានគោល អ្នកពាក់ព័ន្ធសំខាន់ៗក្នុងគម្រោង នឹងត្រូវកំណត់អត្តសញ្ញាណនៅក្នុងសហគមន៍រងការប៉ះពាល់ និងដំណើរការដែលសមស្របតាមប្រពៃណីរបស់ពួកគេ សម្រាប់ការពិគ្រោះយោបល់ជាមួយជនជាតិដើម នៅក្នុងពេលរៀបចំអនុគម្រោង និង ការអនុវត្ត ក៏ត្រូវកំណត់អត្តសញ្ញាណជាមួយអ្នកពាក់ព័ន្ធទាំងនោះផងដែរ (សូមអានវាក្យខ័ណ្ឌ 9 នៃគោលនយោបាយនេះ)។

(ឃ) ការវាយតម្លៃជាមួយសហគមន៍ជនជាតិដើមភាគតិច នូវផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានដែលអាចកើតឡើង ដោយសារគម្រោង ដោយផ្អែកលើគោលការណ៍ណែការពិគ្រោះយោបល់ដោយសេរី ជាមុន និងជាមួយព័ត៌មានគ្រប់គ្រាន់។ ការវាយតម្លៃនេះត្រូវមានការគិតគូរជាពិសេសអំពីភាពងាយរងគ្រោះដោយឡែករបស់សហគមន៍ជនជាតិដើមភាគតិច ដោយគិតគូរផងដែរអំពីភាពស្ថិតនៅឆ្ងាយរបស់ពួកគេ ចំណងទាក់ទងជាមួយដីធ្លី និងធនធានធម្មជាតិ និងកម្រិតកំណត់នៃការទទួលបានឱកាសសម្រាប់ការអភិវឌ្ឍនៅក្នុងសង្គមទាំងមូល។

(ង) ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃ ជាមួយសហគមន៍ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ នូវវិធានការចាំបាច់នានា ដោយផ្អែកលើគោលការណ៍នៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងជាមួយព័ត៌មានគ្រប់គ្រាន់ ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ឬ ប្រសិនបើវិធានការបែបនោះមិនអាចអនុវត្តមាន ត្រូវកំណត់វិធានការដើម្បីកាត់បន្ថយជាអតិបរមា ការបន្ធូរបន្ថយ ឬ ផ្តល់សំណងសម្រាប់ផលប៉ះពាល់បែបនោះ និងត្រូវធានាថា ជនជាតិដើមភាគតិចបានទទួលផលប្រយោជន៍សមស្របពីគម្រោងនេះទៅតាមប្រពៃណីរបស់ពួកគេ។

ក្នុងករណីសហគមន៍ជនជាតិដើមភាគតិច ការវាយតម្លៃសង្គមបែបនេះត្រូវតែបង្ហាញជាជំពូកដាច់ដោយឡែកនៅក្នុង ESMP, ដែលក៏អាចបង្ហាញជូនផងដែរជាឯកសារមួយដាច់ដោយឡែកសម្រាប់គោលដៅនៃការពិគ្រោះយោបល់ និងការបើកចំហ។

## 5.3 ដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់

គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច ទាមទារឲ្យមានដំណើរការនៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ដែលនាំទៅរកការគាំទ្រទូលំទូលាយរបស់សហគមន៍ពីក្រុមជនជាតិដើមភាគតិចដែលទទួលផលពីអនុគម្រោង ឬ ដែលរងការប៉ះពាល់ដោយអនុគម្រោងដែលទទួលហិរញ្ញវត្ថុពីធនាគារពិភពលោក។ គោលការណ៍នៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ទទួលស្គាល់សិទ្ធិពីកំណើត និងពីមុនមក របស់ជនជាតិដើមភាគតិច ចំពោះដីធ្លី ដែនដី និងធនធានរបស់ពួកគេ និងគោរពអំណាចស្របច្បាប់របស់ពួកគេ និងតម្រូវឲ្យមានដំណើរការនានា ដែលអនុញ្ញាត និងគាំទ្រឲ្យមានជម្រើសប្រកបដោយអត្ថន័យពីសំណាក់ជនជាតិដើមភាគតិច អំពីមាគ៌ានៃការអភិវឌ្ឍរបស់ពួកគេ។

ប្រទេសជាអ្នកទទួលឥណទានត្រូវប្រើប្រាស់វិធីពិគ្រោះយោបល់តាមបែបចូលរួម ដែលសមស្របទៅនឹងគុណតម្លៃសង្គម និងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ និងលក្ខខណ្ឌនៅក្នុងមូលដ្ឋានរបស់ពួកគេ ហើយនៅក្នុងការបង្កើតវិធីទាំងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ចំពោះកង្វល់នានារបស់ស្ត្រី យុវជន និងកុមារជនជាតិដើមភាគតិច និងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានឱកាសពីការអភិវឌ្ឍ និងអត្ថប្រយោជន៍នានា។

វេទិកាជម្មតាសម្រាប់ការពិគ្រោះយោបល់គឺជាផ្នែកមួយនៃSIA រីឯវិសាលភាពនៃការពិគ្រោះយោបល់ដែលត្រូវអនុវត្ត នឹងអាស្រ័យជាខ្លាំងទៅតាមគម្រោងជាក់លាក់ និងប្រភេទនៃឥទ្ធិពលដែលត្រូវដោះស្រាយ។ វិធីសាស្ត្រដែលប្រើប្រាស់នឹងអាស្រ័យលើក្រុមសហគមន៍ដែលរងការប៉ះពាល់ពីគម្រោងជាក់លាក់ (ដូចជា ភាពងាយរងគ្រោះរបស់ពួកគេ ភាសា និងអន្តរកម្មជាប្រចាំជាមួយសង្គមមនុស្សភាគច្រើន ឬ សហគមន៍ជិតខាង)។

ដំណើរការពិគ្រោះយោបល់ត្រូវធានាថា៖

- ជនជាតិដើមភាគតិច មិនរងការបង្ខិតបង្ខំ ស្ថិតក្រោមសម្ពាធ ឬ ការបំភិតបំភ័យ ក្នុងជម្រើសអភិវឌ្ឍន៍របស់ពួកគេឡើយ

- ការឯកភាពរបស់ជនជាតិដើមភាគតិច ត្រូវតែទទួលបានក្នុងរយៈពេលគ្រប់គ្រាន់ មុនការចេញបញ្ជា ឬការចាប់ផ្តើមសកម្មភាពណាមួយ និងត្រូវបង្ហាញពីការគោរពទៅតាមលក្ខខណ្ឌពេលវេលារបស់ជនជាតិដើមនៅក្នុងដំណើរការពិគ្រោះយោបល់/ការឯកភាព និង
- ជនជាតិដើមភាគតិច មានព័ត៌មានពេញលេញអំពីវិសាលភាពនិងផលប៉ះពាល់ នៃសកម្មភាពអភិវឌ្ឍន៍ដែលស្នើឡើង មកលើដីធ្លី ធនធាន និងសុខុមាលភាពរបស់ពួកគាត់។ ព័ត៌មានគួរតែបានផ្តល់អំពីប្រភេទ ទំហំ ល្បឿន លទ្ធភាពវិលមកស្ថានភាពដើមវិញ និងទំហំនៃគម្រោង ឬ សកម្មភាពដែលស្នើឡើង, គោលបំណងនៃគម្រោងនេះ និងរយៈពេលគម្រោង, ទីតាំង និងទំហំដែលរងការប៉ះពាល់, ការវាយតម្លៃបឋមអំពីផលប៉ះពាល់សេដ្ឋកិច្ច សង្គមវប្បធម៌ និងបរិស្ថានដែលទំនងជាកើតមាន ដែលរួមទាំង ហានិភ័យដែលអាចមាន, បុគ្គលិកដែលទំនងជាពាក់ព័ន្ធនៅក្នុងការប្រតិបត្តិគម្រោងនេះ, និងនីតិវិធីនានាដែលជាប់ពាក់ព័ន្ធជាមួយគម្រោង។ ដំណើរការនេះអាចរាប់បញ្ចូលជម្រើសនៃការព្យួរទុកការឯកភាពផងដែរ។

ការពិគ្រោះយោបល់ និងការចូលរួម គឺជាសមាសភាគសំខាន់មួយនៃដំណើរការមូលមតិ ហើយដំណើរការពិគ្រោះយោបល់ត្រូវតែមានការចងក្រងជាឯកសារ។

ការចាត់ចែងសម្រាប់ការពិគ្រោះយោបល់ គួរតែមានការពិចារណាដោយប្រុងប្រយ័ត្ន និងរៀបចំឡើងឲ្យស្របតាមបរិបទនៃអនុគម្រោង ផលប៉ះពាល់ដែលរំពឹងទុក និងបរិបទនៃសហគមន៍មូលដ្ឋាន។ ការពិគ្រោះយោបល់នានា គួរតែបានធ្វើឡើងជាភាសារបស់ជនជាតិនោះ ទៅតាមករណីចាំបាច់ និងគួរផ្តល់ពេលវេលាជាមុនតាមការចាំបាច់ (យ៉ាងហោចណាស់ពីរសប្តាហ៍) ដើម្បីធានាថា សហគមន៍ជនជាតិភាគតិចដែលរងការប៉ះពាល់ទាំងអស់ អាចចូលរួមក្នុងការពិគ្រោះយោបល់ដោយមានព័ត៌មានពេញលេញអំពីអនុគម្រោងនេះ។ វិធីពិគ្រោះយោបល់អាចរាប់បញ្ចូលៈ

- ការប្រជុំសហគមន៍ ទាំងជាមួយសហគមន៍ទាំងមូល និងជាមួយអនុក្រុម
- ការពិភាក្សាក្រុមគោលដៅ និងការរៀបចំផែនការតាមបែបចូលរួម
- ការចែកផ្សាយព័ត៌មានអំពីគម្រោងទាំងជាទម្រង់ពេញលេញ (ឯកសារគម្រោង របាយការណ៍វាយតម្លៃ។ល។) ទម្រង់ងាយៗ ដូចជា ផ្ទាំងរូបភាព សន្លឹកព័ត៌មាន និងសម្ភារៈដែលមានជាសម្លេងនិងរូបភាពដោយប្រើប្រាស់ភាសារបស់អ្នកមូលដ្ឋាន។
- ការកំណត់អត្តសញ្ញាណជនសម្រាប់ការទាក់ទងនៅក្នុងសហគមន៍ (ការបណ្តុះបណ្តាលខ្លះអាចសមស្រប ដើម្បីពង្រីកសមត្ថភាពរបស់ពួកគេក្នុងការចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការពិគ្រោះយោបល់)
- ការពាក់ព័ន្ធនៃសហគមន៍ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ អង្គការជនជាតិដើមភាគតិច (IPOs)ប្រសិនបើមាន និងអង្គការសង្គមស៊ីវិល(CSOs) ដទៃទៀតដែលមាននៅក្នុងមូលដ្ឋាន ដែលបានកំណត់ដោយសហគមន៍ជនជាតិដើមភាគតិច និង
- ឱកាសសម្រាប់ការពិគ្រោះយោបល់នៅគ្រប់ដំណាក់កាលនៃការរៀបចំ និងការអនុវត្តគម្រោង។

ក្រុមបេសកកម្មនេះ បានធ្វើការសម្ភាសគ្រួសារនានាដោយចោះៗ ជាមួយសហគមន៍ជនជាតិដើមភាគតិច ពោលគឺ ក្រុមជនជាតិព្នង នៅថ្ងៃទី 16 ខែ មិថុនា ឆ្នាំ 2016។ ដើម្បីមានអនុលោមភាពជាចាំបាច់ជាមួយការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ក្រុមនេះបានធ្វើដំណើរទៅភូមិកំពង់ញ្ញៅ (ឃុំកោះខ្ញែ ស្រុកសំបូរ ខេត្តក្រចេះ) ដែលស្ថិតនៅចុងម្ខាងនៃកំណាត់ផ្លូវដែលបានស្នើឡើង។ ក្នុងគោលដៅកាត់បន្ថយឥទ្ធិពលពីអាជ្ញាធរមូលដ្ឋាន ការចាត់ចែងចូលក្នុងភូមិនេះត្រូវបានប្រកាសត្រឹមបន្តិច បន្ទាប់ពីមានការជួបជាមួយអាជ្ញាធរមូលដ្ឋាន។ ប្រធានភូមិកំពង់ញ្ញៅ បានជូនដំណើរក្រុមបេសកកម្មនេះ ប៉ុន្តែមិនបានស្នើឲ្យមានវត្តមាននៅក្នុងការសម្ភាសឡើយ។ ការជ្រើសរើសគ្រួសារនានាសម្រាប់ការសម្ភាស បានធ្វើឡើងដោយចោះៗ ជាមួយការសម្ភាសដោយចូលជួបផ្ទាល់។ ដើម្បីធានាគុណភាពនៃការប្រមូលទិន្នន័យជាមួយការគិតគូរអំពីយេនឌ័រ ក្រុមទីប្រឹក្សាបានបែងចែកជាពីរផ្នែក។ ក្រុមបុរសក្នុងបេសកកម្មនេះ បានដឹកនាំការសម្ភាសជាមួយបុរស ចំណែកក្រុមអ្នកសម្ភាសនារី ដឹកនាំដោយស្ត្រីជាសមាជិកក្រុមបេសកកម្មនេះ។

ភូមិជនជាតិដើមក្នុងទីដាច់ស្រយាលមួយនេះ ភាគច្រើនអាចចេញចូលបានតាមទូក និងទូកចម្លងក្នុងមូលដ្ឋាន ដោយសារស្ពានមួយដែលតភ្ជាប់ភូមិនេះ ទៅកំណាត់ផ្លូវដែលស្នើឡើង នៅពុំទាន់បានសាងសង់ឡើយទេ។ គម្រោងសាងសង់ស្ពាន ត្រូវបានលើកស្នើនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ប៉ុន្តែពុំមានការផ្តល់មូលនិធិសម្រាប់ការសាងសង់ឡើយ។ អ្នកភូមិត្រូវបង់ថ្លៃទូកចម្លង 2.000 រៀល (ប្រមាណ 0,5 ដុល្លាអាមេរិក) សម្រាប់ដំណើរទៅមក ដែលជាការចំណាយខ្ពស់សម្រាប់សហគមន៍នានា ដែលការរស់នៅពឹងផ្អែកភាគច្រើនលើកសិកម្ម (ការដាំស្រូវតែមួយលើកនៅរដូវវស្សា) ដោយដាំដំណាំនានាដូចជា ដំឡូងមី (នៅរដូវប្រាំង) ការចិញ្ចឹមជ្រូក និងលក់ពលកម្មតាមរដូវទៅឲ្យភូមិ និងស្រុកនៅជិតខាង។ ស្ត្រីអ្នកទទួលការសម្ភាសមួយរូប បានរម្លឹកថា កូនប្រុសគាត់ទៅសាលារៀន។ គាត់ពោលថា កូនប្រុសគាត់ស្នាក់នៅក្នុងវត្ត ជិតសាលារៀន (នៅក្នុងស្រុកនេះ) និងតាមធម្មតា គាត់ត្រូវជិះកង់រយៈពេលពីរម៉ោងដើម្បីមកលេងផ្ទះនៅពេលវិស្សមកាល។

ស្ត្រីទាំងអស់នៅក្នុងការសម្ភាស បានស្វាគមន៍កិច្ចផ្តួចផ្តើមសាងសង់ផ្លូវ និងស្ពាន។ ចំពោះពួកគាត់ កិច្ចផ្តួចផ្តើមបែបនេះផ្តល់ឲ្យពួកគាត់នូវលទ្ធភាពក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជា សាលារៀន ផ្សារ និង សម្បទាសុខភាព។ ស្ត្រីម្នាក់ អាយុ 25 ឆ្នាំ និងជាម្តាយដែលមានកូនប្រាំមួយនាក់ បានពោលថា គាត់បានសម្រាលកូនប្រាំនាក់នៅឯផ្ទះ ដោយមានឆ្មបបូរាណ ទោះបីបានទទួលព័ត៌មានអំពីវិធីសម្រាលកូននៅមណ្ឌលសុខភាពដែលមានសុវត្ថិភាពជាងក៏ដោយ។ គាត់បានរួមចំណែកក្នុងការសម្រេចចិត្តបែបនេះ ដោយសារតែថ្លៃចំណាយ និងរយៈពេលធ្វើដំណើរយ៉ាងវែង ពីកន្លែងរបស់គាត់ទៅមណ្ឌលសុខភាព។

ស្ត្រីភាគច្រើននៅក្នុងការសម្ភាស បានដឹង ឬ យ៉ាងហោចណាស់បានចូលរួមមួយលើកក្នុងការប្រជុំរៀបចំផែនការឃុំ ដែលទាក់ទងនឹងផែនការអភិវឌ្ឍន៍ឃុំ ការសាងសង់ផ្លូវ ការបង្កើនការយល់ដឹងអំពីសុខភាព និងអនាម័យ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលសាកសួរអំពីលក្ខណៈនៃការធ្វើសេចក្តីសម្រេច រវាងពួកគាត់ និងស្វាមី ឬ បុរសដទៃទៀតនៅក្នុងផ្ទះ អំណាចក្នុងការធ្វើសេចក្តីសម្រេច នៅតែស្ថិតក្នុងដៃបុរស នៅពេលពាក់ព័ន្ធនឹងការរួមចំណែកជាដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត។ ទាក់ទងនឹងការរួមវិភាគទានជាដីធ្លី និងទ្រព្យសម្បត្តិ អ្នកភូមិនៅក្នុងការសម្ភាសនេះគ្មានស្ម័គ្រចិត្តផ្តល់វិភាគទាន ដោយគ្មានលក្ខខណ្ឌឡើយ ប្រសិនបើការសាងសង់ផ្លូវដែលស្នើឡើងប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ពួកគាត់។ ស្ត្រីចំណាស់ម្នាក់ បានកត់សំគាល់ថា ផ្ទះរបស់គាត់ងាយស្រួលសង់ និងមិនចាំបាច់ចំណាយច្រើនឡើយ។ ប្រពៃណីរបស់ពួកគាត់គាំទ្រដល់ការជួយគ្នា

ក្នុងការសង់ជម្រក។ និយាយម៉្យាងទៀតថា អ្នកជិតខាងរបស់គាត់ នឹងជួយគាត់ ប្រសិនបើគាត់ត្រូវការកម្លាំងពលកម្មដើម្បីសង់ផ្ទះ និងផ្ទុយមកវិញគ្រួសារគាត់អាចផ្តល់ការគាំទ្រផងដែរ ប្រសិនបើអ្នកជិតខាងត្រូវការ។

គួរកត់សំគាល់ផងដែរថា អំពើហិង្សាក្នុងគ្រួសារ និងការសេពគ្រឿងស្រវឹង មានអត្រាខ្ពស់ជាបង្គួរ នៅក្នុងសហគមន៍នេះ។ ស្ត្រីចំណាស់ម្នាក់បានពោលថា 5ក្នុងចំណោម 10គ្រួសារ ធ្លាប់មានអំពើហិង្សាក្នុងគ្រួសារ។ អត្រាសេពសុរាកម្រិតខ្ពស់ក្នុងចំណោមស្ត្រី ក៏បានបង្ហាញយ៉ាងច្បាស់ផងដែរ។ ការសម្លាប់សមួយ ក្នុងចំណោមការសម្លាប់ប្រាំគ្រួសារ ត្រូវបានរំខានដោយសារសមាជិកម្នាក់ក្នុងគ្រួសារស្រវឹង និងរំខាននៅក្នុងការ សម្លាស។ ស្ត្រីចំណាស់នោះបានភ្ជាប់ការសេពសុរា ជាមូលហេតុចំបងមួយនៃអំពើហិង្សាក្នុងគ្រួសារ។ គួរឲ្យចាប់អារម្មណ៍ផងដែរថា គាត់បានកត់សំគាល់ថា ភាពងាយស្រួលក្នុងការទៅកាន់ទីផ្សារ តាមរយៈហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងមុន នឹងបង្កើនការជួញដូរ ប៉ុន្តែក៏នឹងនាំឲ្យមានឥទ្ធិពលអវិជ្ជមានផងដែរ។ គាត់បានពោលថា សមាជិកសហគមន៍របស់គាត់អាចសេពកាន់តែច្រើននូវគ្រឿងស្រវឹងដែលមានលក់នៅទីផ្សារ ធៀបនឹងស្រាដែលពួកគាត់បានផលិតតាមប្រពៃណី ដែលនាំឲ្យមានការពុលស្រា និងការបាត់បង់ជីវិតថ្មីៗនេះនៅក្នុងសហគមន៍។

## 5.4 ការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច

យោងតាម OP/BP 4.10 នៅពេលការជ្រើសរើសបានបង្ហាញឲ្យឃើញថា ទំនងជាមានជនជាតិដើមភាគតិច ជាមួយសម្ព័ន្ធភាពជាសមូហភាពរបស់ពួកគេទៅនឹងទីតាំងអនុគម្រោង នៅក្នុងតំបន់គម្រោងនេះ របកគំហើញពីដំណើរការ SIA និងការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ នឹងត្រូវប្រើប្រាស់ដោយដៃគូអនុវត្ត ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) សម្រាប់អនុគម្រោងជាក់លាក់ដែលប៉ះពាល់ដល់ជនជាតិភាគតិច។ IPDP ត្រូវបង្កើតវិធានការនានាដែលតាមរយៈវិធានការទាំងនោះ ប្រទេសអ្នកទទួលឥណទានត្រូវធានាថា៖ (ក) ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ពីគម្រោង ទទួលបានអត្ថប្រយោជន៍ខាងសង្គមនិងសេដ្ឋកិច្ច ដែលសមស្របតាមប្រពៃណី និង (ខ) នៅពេលដែលផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានមកលើជនជាតិដើមភាគតិចត្រូវបានរកឃើញហើយនោះ ត្រូវបញ្ចៀស កាត់បន្ថយបន្ធូរបន្ថយ ឬ ផ្តល់សំណងសម្រាប់ផលប៉ះពាល់អវិជ្ជមានទាំងនោះ។ គួររៀបចំ IPDP តាមវិធីដែលផ្តល់ភាពបត់បែនបាន និងមានភាពជាក់ស្តែង ហើយកម្រិតពិស្តារអាចខុសគ្នា អាស្រ័យទៅតាមអនុគម្រោងជាក់លាក់ និងប្រភេទនៃផលប៉ះពាល់ដែលត្រូវដោះស្រាយ។ ប្រទេសអ្នកទទួលឥណទាន ត្រូវដាក់បញ្ចូលIPDP ទៅក្នុងរចនាសម្ព័ន្ធនៃគម្រោង។

ក្នុងករណីចាំបាច់ នៅក្នុង IPDP គួរតែមានរួមបញ្ចូលចំណុចនានាតាមការចាំបាច់ (ដែលសមាមាត្រនឹងវិសាលភាព អត្ថប្រយោជន៍ ផលប៉ះពាល់ និងហានិភ័យនៃអនុគម្រោងនោះ) ដូចតទៅ៖

ក) សេចក្តីអធិប្បាយអំពីគម្រោង និងសេចក្តីអធិប្បាយសង្ខេបអំពីបញ្ហានានាដែលទាក់ទងនឹងជនជាតិដើមភាគតិច

ខ) សេចក្តីសង្ខេបមួយអំពីក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច

គ) សេចក្តីសង្ខេបអំពីការវាយតម្លៃសង្គម ដែលរួមទាំងព័ត៌មានគោលអំពីប្រជាសាស្ត្រ សង្គម វប្បធម៌ និងនយោបាយរបស់ជនជាតិភាគតិចដែលរងការប៉ះពាល់ ដីធ្លី និងដែនដីដែលពួកគេធ្លាប់ធ្វើជាម្ចាស់ ឬប្រពៃណីដែលជាមូលដ្ឋាននៃការកាន់កាប់និងធនធានធម្មជាតិជាបង្អែកនៃការចិញ្ចឹមជីវិតរបស់ពួកគេ

ឃ) សេចក្តីសង្ខេបអំពីលទ្ធផលនៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ជាមួយជនជាតិភាគតិចដែលរងការប៉ះពាល់ ដែលនាំទៅរកការគាំទ្រទូលំទូលាយពីសហគមន៍ចំពោះអនុគម្រោងនោះ

ង) ក្របខ័ណ្ឌមួយដើម្បីធានាឲ្យមានការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ជាមួយជនជាតិភាគតិចដែលរងការប៉ះពាល់ នៅក្នុងពេលអនុវត្តសកម្មភាពអនុគម្រោង

ច) វិធានការនានាដើម្បីធានាថា ជនជាតិភាគតិចដែលរងការប៉ះពាល់ ទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ច ដែលមានលក្ខណៈសមស្របតាមប្រពៃណីរបស់ពួកគេ

ឆ) សេចក្តីអធិប្បាយមួយអំពីការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្ត IPDP

ជ) វិធានការនានាដើម្បីបញ្ចៀស កាត់បន្ថយ បន្ធូរបន្ថយ ឬ ផ្តល់សំណងសម្រាប់ផលប៉ះពាល់អវិជ្ជមាន

៣) ការប៉ាន់ស្មានថ្លៃចំណាយ និងផែនការហិរញ្ញប្បទានសម្រាប់ IPDP

ដ) យន្តការដោះស្រាយបណ្តឹងសារទុក្ខដែលជនជាតិភាគតិចរងការប៉ះពាល់ អាចប្រើប្រាស់បាន និង

ឋ) ការតាមដាន ការវាយតម្លៃ និងការរាយការណ៍ អំពីការអនុវត្ត IPDP ទន្ទឹមនឹងសូចនាករតាមដានជាក់លាក់ (ញែកដាច់គ្នាទៅតាមក្រុមជនជាតិ)។

នៅពេលដែលមានតែជនជាតិដើមភាគតិចគឺជាអ្នកទទួលផល ឬ ភាគច្រើនបំផុត គឺជាអ្នកទទួលផលដោយផ្ទាល់ពីគម្រោង ជាតុផ្សំនៃ IPDP គួរតែបានដាក់បញ្ចូលទៅក្នុងទម្រង់រួមនៃគម្រោង ដោយពុំចាំបាច់មាន IPDP ដាច់ដោយឡែកឡើយ។ ក្នុងករណីបែបនោះ ជាតុផ្សំសំខាន់ៗនៃ IPDP (សូមអានចំណុច ខ-ដ) នឹងត្រូវដាក់បញ្ចូលទៅក្នុង ESMP សម្រាប់អនុគម្រោងដែលពាក់ព័ន្ធ ទន្ទឹមនឹងរបកគំហើញនៃការវាយតម្លៃសង្គម។ ឯកសារ ESMP ដែលរៀបចំឡើងស្របគ្នានេះ នឹងអាចទទួលយកបាន តែក្នុងករណីដែលជាតុផ្សំទាំងនេះ ត្រូវបានបញ្ចូល ដែលអាចឲ្យអង្គភាពគ្រប់គ្រងគម្រោង និងក្រុមវាយតម្លៃគម្រោងរបស់ធនាគារពិភពលោកទទួលយកបាន។ ការចាត់ចែងស្ថាប័ន។

នៅកម្ពុជា ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) ទទួលបន្ទុកលើការអភិវឌ្ឍ និងការគ្រប់គ្រងផ្លូវថ្នល់ ប៉ុន្តែក្រសួងអភិវឌ្ឍន៍ជនបទ (MRD), ក្រសួងការពារជាតិ (MND) និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ក៏ពាក់ព័ន្ធនៅក្នុងសកម្មភាពទាំងនេះផងដែរ។ MPWT ទទួលខុសត្រូវភាគច្រើនតែលើការរៀបចំផែនការ និងការអនុវត្ត ផ្លូវ(អន្តរ)ជាតិ និងខេត្ត។ ស្ថាប័នដទៃទៀត ពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍផ្លូវលំជនបទ ឬក្នុងសកម្មភាពនានា ដែលធ្វើឡើងនៅក្នុងតំបន់គ្រោះថ្នាក់ ដែលការបោសសំអាតគ្រាប់មីន គឺជាការចាំបាច់ នៅមុនការសាងសង់អាចចាប់ផ្តើមបាន ឬ ក្នុងតំបន់ដែលមានអាសន្ន ដូចជា MND។

គម្រោង SEA DRM សម្រាប់កម្ពុជា នឹងត្រូវអនុវត្តដោយគោរពតាមប្រព័ន្ធរបស់រដ្ឋាភិបាល។ ការិយាល័យគ្រប់គ្រងគម្រោង (PMO) នៃទីភ្នាក់ងារអនុវត្ត (DIA) ក្នុងក្រសួង MRD មានភារៈទទួលខុសត្រូវលើសកម្មភាពបច្ចេកទេស ដែលត្រូវអនុវត្តដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (PDRD) នៅក្រោមគម្រោង SEA DRM សម្រាប់កម្ពុជា។ ថ្នាក់ដឹកនាំសាលាខេត្តនឹងមានភារៈទទួលខុសត្រូវលើការរៀបចំផែនការអនុគម្រោង និងការអនុវត្តនៅថ្នាក់ខេត្ត តាមរយៈ PDRD ចំណែកការរៀបចំផែនការ និងការអនុវត្តនៅកម្រិតគម្រោង នឹងត្រូវដឹកនាំដោយ PMOs នៅថ្នាក់ស្រុក។ ស្រុកនិងឃុំ ស្ថិតក្រោមអំណាចរបស់ថ្នាក់ដឹកនាំខេត្ត។ សាលាខេត្តធ្វើសេចក្តី

ជូនដំណឹងទៅស្រុក និងឃុំ ដើម្បីចាត់តាំងជនបង្គោលសម្រាប់ធ្វើការជាមួយក្រុមការពារសុវត្ថិភាពបរិស្ថាននិងសង្គមនៃ MRD សម្រាប់អនុគម្រោងនីមួយៗ។

ការិយាល័យការពារសុវត្ថិភាពបរិស្ថាន និងសង្គម(SEO) នៃ MRD ត្រូវមានភារៈទទួលខុសត្រូវលើការអនុវត្ត និងតាមដានកិច្ចការពារសុវត្ថិភាពសម្រាប់ការកែលម្អផ្លូវលំជនបទ។ ទោះបីមានគោលការណ៍ណែនាំស្រាប់អំពីកិច្ចការពារសុវត្ថិភាពសម្រាប់ការកែលម្អផ្លូវលំជនបទហើយក៏ដោយ ការយល់ដឹងអំពីបញ្ហាសុវត្ថិភាពបរិស្ថាន និងសង្គម នៅមានកម្រិតកំណត់ និងទាមទារឲ្យមានសមត្ថភាពថែមទៀត តាមរយៈគោលការណ៍ណែនាំច្បាស់លាស់អំពីកិច្ចការពារសុវត្ថិភាពនិងឯកសារនីតិវិធី។ ក្រសួងបរិស្ថាន ក៏ត្រូវមានភារៈទទួលខុសត្រូវផងដែរក្នុងការផ្តល់វគ្គបណ្តុះបណ្តាលអំពីកិច្ចការពារសុវត្ថិភាព ដោយធានាឲ្យមានការបញ្ជ្រាបលក្ខខណ្ឌការពារសុវត្ថិភាពទៅក្នុងវដ្តគម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់ និងអនុវត្តសកម្មភាពស្រាវជ្រាវ។ លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានកិច្ចការតាំងទីលំនៅឡើងវិញ (អតីតគណៈកម្មការដោះស្រាយបញ្ហានៃការតាំងទីលំនៅឡើងវិញ) នឹងមានការពាក់ព័ន្ធ ដោយសារតម្រូវការមិនអាចជៀសវាងបាន ក្នុងការធ្វើលទ្ធកម្មដីធ្លីជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍។

MRD គឺជាស្ថាប័នអនុវត្ត (DIA) សម្រាប់គម្រោង SEA DRM សម្រាប់កម្ពុជា។ ការិយាល័យគ្រប់គ្រងគម្រោងនៃ MRD ត្រូវរ៉ាប់រងការទទួលខុសត្រូវលើដំណើរការបរិស្ថាន និងសង្គមនៃអនុគម្រោង ដែលអនុវត្តជាមួយការគាំទ្រពី MOE និង IRC។ PMO ថ្នាក់កណ្តាលគួរតែមានបុគ្គលិកសម្រាប់គោលបំណងនេះ ដោយមានមន្ត្រីការពារសុវត្ថិភាពបរិស្ថាន និងសង្គម។ អាស្រ័យលើការបណ្តុះបណ្តាល និងបទពិសោធន៍វិជ្ជាជីវៈ លើការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម បុគ្គលិកទាំងនេះទំនងជាត្រូវការឲ្យមានការបណ្តុះបណ្តាល និងការគាំទ្រជាបន្ថែម។ ពួកគេគួរតែបានទទួលការគាំទ្រពីក្រុមទីប្រឹក្សាជំនួយបច្ចេកទេស (TA) ដែលនឹងជួយនៅក្នុងការអនុវត្តលក្ខខណ្ឌនៃ ESMF ទន្ទឹមនឹងកសាងសមត្ថភាពរបស់បុគ្គលិកដើម្បីដោះស្រាយបញ្ហាការពារសុវត្ថិភាពផងដែរ។

នៅពេលដែលបានកំណត់អត្តសញ្ញាណអនុគម្រោងរួចហើយ ការិយាល័យគ្រប់គ្រងគម្រោងនៃ DIA (នៅក្រោម MRD) ត្រូវគូសបញ្ជាក់អំពីករណីយកិច្ច និងការទទួលខុសត្រូវ ដែលទាក់ទងនឹងការអនុវត្តអនុគម្រោងជាក់លាក់។ PMOs នៅថ្នាក់កណ្តាល ត្រូវពិនិត្យរបាយការណ៍ជ្រើសរើស ដែលរៀបចំដោយ PMOs នៅមូលដ្ឋាន និងរៀបចំសេចក្តីព្រាងលក្ខខណ្ឌយោងសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម(ESMP) និងលក្ខខណ្ឌនានា ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច(IPDP)។ ESMP និងឯកសារផែនការ (ពោលគឺ ARAP និង IPDP) នឹងត្រូវចែករំលែកជាមួយអ្នកពាក់ព័ន្ធនានា និងក្រុមប្រជាពលរដ្ឋខុសៗគ្នា នៅក្នុងពេលពិគ្រោះយោបល់។ បញ្ហានានា និងការសង្កេត ដែលបានកត់សំគាល់ នៅក្នុងការពិគ្រោះយោបល់ នឹងត្រូវដាក់បញ្ចូល។ ឯកសារដែលបានចងក្រង នឹងត្រូវចែករំលែកសម្រាប់ការបើកចំហជាសាធារណៈ និងដាក់ជូនទៅធនាគារពិភពលោកដើម្បីពិនិត្យ។

សមាសភាគគ្រប់គ្រងគម្រោង (សមាសភាគ 3) នៃគម្រោង DRM សម្រាប់កម្ពុជា នឹងជួយដល់ការគ្រប់គ្រង និងអនុវត្តអនុគម្រោងនានា ដែលរួមទាំង ការគាំទ្រខាងស្ថាប័ន និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការគ្រប់គ្រងគម្រោង ការសម្របសម្រួល ទិដ្ឋភាពបច្ចេកទេស និងកិច្ចការពារសុវត្ថិភាព ដែលរួមទាំង ការអនុវត្ត IPPF និងវិធានការនានា ដែលបានបញ្ចូលនៅក្នុង IPPs, ការតាមដាន និងវាយតម្លៃ និង ការរាយការណ៍ផងដែរ

។ ថ្លៃចំណាយលើការអនុវត្ត ESMF នឹងរួមបញ្ចូលការរៀបចំលិខិតូបករណ៍ការពារសុវត្ថិភាពតាមទីតាំងជាក់លាក់ ដែលរួមទាំង ថ្លៃចំណាយលើបុគ្គលិក ថ្លៃធ្វើដំណើរ សិក្ខាសាលាពិគ្រោះយោបល់ ការបកប្រែ និងការបណ្តុះបណ្តាល។ សន្ទស្សន៍ថ្លៃចំណាយសរុប ត្រូវបានពិនិត្យដោយធនាគារពិភពលោក និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានប៉ាន់ស្មានត្រឹម 205.000 ដុល្លាអាមេរិក (**Error! Reference source not found.** ដែលនឹងបានការគាំទ្ររួមគ្នាពី IDA និងថវិកាបដិភាគ ពីសមាសភាគគ្រប់គ្រងគម្រោង។

## 6.0 ការចាត់ចែងតាមដាន និងវាយតម្លៃ

គម្រោង SEA DRM សម្រាប់កម្ពុជា នឹងអនុវត្តការតាមដាន និងវាយតម្លៃជនជាតិដើមភាគតិច និងជាពិសេស អំពីថាតើការងារផ្លូវលំដែលស្តារឡើងវិញ ប៉ះពាល់ជនជាតិដើមភាពតិចបែបណា ទាំងវិជ្ជមាន និងអវិជ្ជមាន។ ប្រសិនបើជនជាតិភាគតិចរងការប៉ះពាល់អវិជ្ជមានដោយសារតែលទ្ធកម្មដីធ្លី ឬ សម្បត្តិដទៃទៀត ក្នុងករណីនោះការតាមដាន និងវាយតម្លៃ នឹងពិនិត្យមើលលទ្ធកម្មដីធ្លី ការកំទេចនិងការប្តូរទីតាំងរបស់ជនជាតិដើមភាគតិច ហើយនីតិវិធីនានាត្រូវចងក្រងជាឯកសារនៅក្នុង ARAPនេះ។

លើសពីនេះ តាមលក្ខខណ្ឌតម្រូវនៅក្នុង ESMF របាយការណ៍តាមដាននឹងត្រូវធ្វើឡើងប្រចាំខែ ត្រីមាស និងឆមាស ទៅតាមសកម្មភាពជាក់លាក់ដើម្បី៖

- កែលម្អទម្លាប់ក្នុងការគ្រប់គ្រងបរិស្ថាន និងសង្គម
- ធានាប្រសិទ្ធភាព និងគុណភាពនៃដំណើរការវាយតម្លៃបរិស្ថាន និងសង្គម
- បង្កើតការវាយតម្លៃបរិស្ថាន និងសង្គមដែលផ្អែកលើភស្តុតាង និងលទ្ធផលសម្រាប់អនុគម្រោង និង
- ផ្តល់ឱកាសដើម្បីរាយការណ៍អំពីលទ្ធផលនៃកិច្ចការពារសុវត្ថិភាព ផលប៉ះពាល់និងការអនុវត្តវិធានការកាត់បន្ថយដែលស្នើឡើង។

ទាក់ទងនឹងគម្រោង DRM សម្រាប់កម្ពុជា ដែលរួមទាំង ការអនុវត្តសំណើកិច្ចផ្តួចផ្តើមអនុគម្រោង និង/ឬសកម្មភាពនានា ការិយាល័យគ្រប់គ្រងគម្រោង (PMO) នៃក្រសួងអភិវឌ្ឍន៍ជនបទ នឹងអនុវត្តសកម្មភាពតាមដានផ្ទៃក្នុង និងសិក្សាលទ្ធភាព និង ESMPs ដើម្បីកំណត់វិសាលភាពដែលវិធានការកាត់បន្ថយត្រូវបានអនុវត្តដោយជោគជ័យ។ SEO ត្រូវអនុវត្តសកម្មភាពតាមដានផ្ទៃក្នុងប្រចាំត្រីមាស និងត្រូវដាក់ជូនរបាយការណ៍មក IRC និងធនាគារពិភពលោកដើម្បីពិនិត្យ។ ការតាមដាន នឹងផ្តោតលើផ្នែកសំខាន់ៗចំនួនបី៖

*(i)* *ការតាមដានលើអនុលោមភាព៖* ដើម្បីផ្ទៀងផ្ទាត់ថាតើវិធានការកាត់បន្ថយ ត្រូវបានពិចារណា និងបានអនុវត្តឬទេ។ នៅក្នុងដំណាក់កាលនៃការរៀបចំអនុគម្រោង សកម្មភាពតាមដានអនុលោមភាព នឹងផ្តោតលើការធានាឲ្យមានការអនុវត្ត ESMF និងការគោរពតាមនីតិវិធីនានា។ បុគ្គលិកឯកទេសបរិស្ថាន និងសង្គមក្នុងការិយាល័យ PMO នៃក្រសួង MRD នឹងធានាថា ការសិក្សាក្នុងអនុគម្រោងនៃ SEA សម្រាប់កម្ពុជា ធ្វើឡើងបានត្រឹមត្រូវ និងយ៉ាងឆាប់រហ័ស ស្របតាមច្បាប់របស់កម្ពុជានិងងបទប្បញ្ញត្តិរបស់ក្រុមធនាគារពិភពលោក។

ការសិក្សាលទ្ធភាពក៏ត្រូវគិតបញ្ចូលផងដែរ នូវការវាយតម្លៃអំពីលក្ខខណ្ឌសម្រាប់ការអនុវត្តសកម្មភាពដែលទាក់ទងនឹង ARAP/RAP និង IPDP។

- បណ្តឹងសារទុក្ខ ជាពិសេសបណ្តឹងដែលនៅពុំទាន់បានដោះស្រាយ នៅកម្រិតមូលដ្ឋាន និងដែលអាចទាមទារឲ្យមានដំណោះស្រាយនៅកម្រិតខ្ពស់ជាង ដូចដែលបានកំណត់តាំងពីដំបូងនៅក្នុង ESMF
- ការបំពេញឯកសារអំពីការតាំងទីលំនៅឡើងវិញនៅក្រោមគម្រោង និងការទូទាត់សំណង ប្រសិនបើប្រការទាំងនេះអាចអនុវត្តបាន ដែលរួមទាំង ការបាត់បង់ជាអចិន្ត្រៃយ៍ និងជាបណ្តោះអាសន្នផងដែរ។
- ការវាយតម្លៃគុណភាពនៃសំណង ឬ វិធានការកាត់បន្ថយដទៃទៀត ដែលអាចអនុវត្តបាន ស្របតាមលក្ខខណ្ឌនៃគម្រោងវិនិយោគដែលមានសក្តានុពលសម្រាប់អនាគត ដែលបានកំណត់ឃើញតាំងពីដើមដំបូង ដែលរួមទាំង ផលប៉ះពាល់មកលើបរចិញ្ចឹមជីវិតផងដែរ និង
- វិធានការកាត់បន្ថយនានា នៅពេលមានការប្រែប្រួលជាសំខាន់នៃសូចនាករ ដែលអាចទាមទារឲ្យមានអន្តរាគមន៍ជាយុទ្ធសាស្ត្រ ដូចជា ប្រសិនបើក្រុមប្រជាពលរដ្ឋ (ជនជាតិភាគតិច) និងក្រុមជនងាយរងគ្រោះ - ស្ត្រី យុវតី/យុវជន កុមារ បុរស មនុស្សចាស់ ជនពិការ អ្នកគ្មានដីធ្លី និងជនក្រីក្រ ។ល។) មិនបានទទួលការគាំទ្រគ្រប់គ្រាន់ពីអនុគម្រោងដែលមានសក្តានុពល។

នៅក្នុងដំណាក់កាលអនុវត្ត ការតាមដានលើអនុលោមភាព អាចរាប់បញ្ចូល អធិការកិច្ច នៅក្នុងអំឡុងពេលសាងសង់នៅក្រោមកិច្ចផ្តួចផ្តើមនិង/ឬសកម្មភាពនៃអនុគម្រោង ដើម្បីផ្ទៀងផ្ទាត់ វិសាលភាពនៃលក្ខខណ្ឌនានានិងអាជ្ញាប័ណ្ណដែលបានផ្តល់ជូន និងត្រូវបានគោរពតាម។ ប្រសិទ្ធភាពនៅក្នុងដំណាក់កាលសាងសង់ ដំណាក់កាលដាក់ឲ្យដំណើរការ និងការកំទេចចោល សម្រាប់គម្រោងណាមួយ ត្រូវតែជាការទទួលខុសត្រូវទាំងស្រុងនៃក្រសួង MRD និងការតាមដានអនុលោមភាពត្រូវធានាដោយក្រសួងបរិស្ថាន។

(ii) *ការតាមដានលើផលប៉ះពាល់៖* នៅពេលអនុវត្ត ការតាមដានលើវិធានការកាត់បន្ថយផលប៉ះពាល់នៃកិច្ចផ្តួចផ្តើម និង/ឬសកម្មភាពនៃអនុគម្រោង គួរតែជាកាតព្វកិច្ចរបស់ DIA និងSEO។ មានការរំពឹងថា ឯកសារការពារសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវតែបានផ្តល់ទៅឲ្យអ្នកម៉ៅការ ហើយ DIA ត្រូវតាមដានឲ្យឃើញថា ការងារនានាប្រព្រឹត្តទៅស្របតាមវិធានការកាត់បន្ថយដែលបានឯកភាព (រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមធនាគារពិភពលោក)។

ការតាមដាន និងវាយតម្លៃ ផលប៉ះពាល់សង្គម ត្រូវវាស់ដូចតទៅ៖

- ផលប៉ះពាល់មកលើបុគ្គល ក្រុមប្រជាជនខុសៗគ្នា គ្រួសារ និងសហគមន៍ ដែលត្រូវរក្សាស្តង់ដារនៃការរស់នៅក្នុងកម្រិតដែលមាននៅមុនគម្រោង ឬ ឲ្យបានប្រសើរជាងនេះ
- ផលប៉ះពាល់ខុសគ្នារវាងយេនឌ័រ ដែលត្រូវជៀសវាង កាត់បន្ថយ ឬ ដោះស្រាយ
- ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍ដែលរងការប៉ះពាល់ពីគម្រោងនៅក្រោយបញ្ចប់គម្រោង និង
- ការគ្រប់គ្រងទំនាស់ឬ ជម្លោះ។

ដើម្បីវាស់ផលប៉ះពាល់ទាំងនេះ ការសិក្សាបុរេលទ្ធភាព ត្រូវកំណត់៖

- សូចនាករជាក់លាក់សម្រាប់ការតាមដាន ជាមួយទិន្នន័យដែលញែកដាច់គ្នាតាមយេនឌ័រ
- កំណត់របៀបធ្វើការវាស់វែងសូចនាករជាទៀងទាត់ និង

- កំណត់ចំណុចគោលសំខាន់ៗសម្រាប់ការតាមដាន (ដូចជា នៅដំណាក់កាលកណ្តាលនៃដំណើរការអនុវត្ត ARAP ប្រសិនបើអាចធ្វើបាន)។

IRC អាចជួលអ្នកតាមដានឯករាជ្យ ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់ដែលទាក់ទងនឹងគម្រោងដែលមានសក្តានុពល ដោយអាស្រ័យលើប្រភេទ និងវិសាលភាពនៃផលប៉ះពាល់។ របាយការណ៍នេះនឹងត្រូវដាក់ជូនមក IRC និងធនាគារពិភពលោក។

*ការតាមដានលើផលប៉ះពាល់ត្រួតគ្នា៖* ផលប៉ះពាល់នៃកិច្ចផ្តួចផ្តើម និង/ឬ សកម្មភាពអនុគម្រោង មកលើធនធានបរិស្ថាន និងសង្គម សម្រាប់ខេត្តនីមួយៗទាំងប្រាំមួយ ក៏ត្រូវតែតាមដានផងដែរ ដោយពិចារណាអំពីការអភិវឌ្ឍនានាដទៃទៀត ដែលអាចកើតមានផងដែរ។

ដើម្បីធានាថាជនជាតិដើមភាគតិចបានចូលរួមនៅក្នុងដំណើរការតាមដាន និងវាយតម្លៃ ក្រុមតាមដានមួយនឹងត្រូវបង្កើតឡើង ក្នុងចំណោមភូមិដែលទទួលផល។ សមាសភាពនៃគណៈកម្មការនេះត្រូវតែបង្កើតឡើងអនុវត្តតាមដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ និងត្រូវផ្អែកលើរចនាសម្ព័ន្ធធ្វើការសម្រេចដោយឡែករបស់សហគមន៍ជនជាតិដើមនីមួយៗ ក៏ដូចជា លក្ខខណ្ឌសម្រាប់តុល្យភាពយេនឌ័រ និងវាងជំនាន់មនុស្សផងដែរ។ ក្រុមតាមដានទាំងនេះ នឹងពិនិត្យរបាយការតាមដានបរិស្ថាន និងសង្គម ដូចបានអធិប្បាយខាងលើ ក៏ដូចជា របាយការណ៍ប្រចាំត្រីមាស ដែលត្រូវរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ អំពីស្ថានភាពនៃការអនុវត្តអនុគម្រោង។ លើសពីនេះ ជារៀងរាល់ឆ្នាំ ប្រធានភូមិ ត្រូវពិនិត្យសកម្មភាពអនុគម្រោង ដែលកំពុងអនុវត្ត នៅក្នុងព្រំដែននៃភូមិរបស់ខ្លួន ដើម្បីបញ្ជាក់ថាតើ ការសាងសង់ ការចាត់ចែងកិច្ចសន្យា និងទិដ្ឋភាពដទៃទៀតត្រូវបានអនុវត្តសមស្របដែរឬទេ។ អាជ្ញាធរគម្រោង ត្រូវធ្វើអធិការកិច្ចទៀងទាត់ និងតាមដានការអនុវត្តផែនការ IPDP។

## 7.0 យន្តការបណ្តឹងសារទុក្ខ

អាជ្ញាធរខេត្តត្រូវបង្កើតគណៈកម្មការដោះស្រាយបណ្តឹងសារទុក្ខ នៅថ្នាក់មូលដ្ឋាន (ខេត្ត ស្រុក និងឃុំ) ដែលត្រូវដឹកនាំដោយ អភិបាល ឬ អភិបាលរងខេត្ត អភិបាលស្រុក និងមេឃុំ។ ក្នុងយន្តការដោះស្រាយបណ្តឹងនៅថ្នាក់ឃុំ សមាជិកយន្តការនេះ មានតំណាងពីក្នុងចំណោមគ្រួសារដែលរងការប៉ះពាល់ (AHs) ដែលនឹងត្រូវជ្រើសយកពីក្នុងចំណោម PAPs។ ក្នុងករណីសហគមន៍ជនជាតិដើមភាគតិច គណៈកម្មការថ្នាក់ភូមិនឹងត្រូវបង្កើតឡើង និងត្រូវគោរពតាមដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ និងត្រូវផ្អែកលើរចនាសម្ព័ន្ធធ្វើការសម្រេចដោយឡែករបស់សហគមន៍ជនជាតិដើមនីមួយៗ ក៏ដូចជាលក្ខខណ្ឌសម្រាប់តុល្យភាពយេនឌ័រ និងវាងជំនាន់មនុស្សផងដែរ។ គណៈកម្មការទាំងនេះនឹងទទួល វាយតម្លៃ និងសម្រួលឲ្យមានដំណោះស្រាយកង្វល់ បណ្តឹង និងការទាមទាររបស់ PAP និង PAH។ គណៈកម្មការដោះស្រាយបណ្តឹងត្រូវដំណើរការ ដើម្បីជាប្រយោជន៍សម្រាប់ PAP និងPAH នៅក្នុងអំឡុងពេលនៃអនុគម្រោងទាំងមូល ដែលរួមទាំងក្នុងអំឡុងពេលជាប់កិច្ចសន្យាជួលជុលការខូចខាតនៅក្រោយបញ្ចប់គម្រោងផងដែរ។

*ដំណាក់កាលដំបូង - នៅថ្នាក់ភូមិ*

គ្រួសារដែលរងការប៉ះពាល់ដោយសារគម្រោង អាចដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅគណៈកម្មការដោះស្រាយបណ្តឹងនៅថ្នាក់ភូមិ នៅក្រោម IPDP។ គណៈកម្មការនេះគួរតែព្យាយាមដោះស្រាយបណ្តឹងនៅក្នុងរយៈ

ពេល 15 ថ្ងៃ បន្ទាប់ពីបានទទួលបណ្ដឹងពីគ្រួសារដែលរងការប៉ះពាល់នោះ។ សមាសភាពនៃគណៈកម្មការនេះនឹងខុសគ្នាអាស្រ័យលើភូមិ និងត្រូវគោរពតាមដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ និងត្រូវផ្អែកលើចេតនាសម្ព័ន្ធធ្វើការសម្រេចដោយខ្លួនឯងរបស់សហគមន៍ជនជាតិដើមនីមួយៗ ក៏ដូចជា លក្ខខណ្ឌសម្រាប់តុល្យភាពយេនឌ័រ និងរវាងជំនាន់មនុស្សផងដែរ។ ប្រសិនបើក្រោយរយៈពេល 15ថ្ងៃ គ្រួសារដែលដាក់ពាក្យបណ្ដឹងមិនបានទទួលព័ត៌មានពីអាជ្ញាធរភូមិ ឬប្រសិនបើគ្រួសាររងការប៉ះពាល់មិនពេញចិត្តចំពោះការសម្រេចធ្វើឡើងនៅក្នុងដំណាក់កាលដំបូង ពួកគេបន្តបណ្ដឹងនោះទៅការិយាល័យស្រុកជាលាយលក្ខអក្សរ ឬ ដោយផ្ទាល់មាត់។

*ដំណាក់កាលទីពីរ - នៅថ្នាក់ឃុំ*

គ្រួសារដែលរងការប៉ះពាល់ដោយសារគម្រោងអាចដាក់ពាក្យបណ្ដឹងរបស់ខ្លួនទៅមេឃុំ។ មេឃុំអាចកោះប្រជុំក្រុមការងារដោះស្រាយបណ្ដឹង ដើម្បីសម្រេចអំពីចំណាត់ការ ក្នុងការដោះស្រាយបណ្ដឹងនៅក្នុងរយៈពេល 15 ថ្ងៃ បន្ទាប់ពីបានទទួលបណ្ដឹងពីគ្រួសារដែលរងការប៉ះពាល់នោះ។ ការប្រជុំរបស់ក្រុមនេះគួរតែមានការចូលរួមពីមេឃុំ តំណាងការិយាល័យ PRSC-WG នៅថ្នាក់ស្រុក និងគ្រួសារដែលដាក់ពាក្យបណ្ដឹង។ មេឃុំមានភារៈទទួលខុសត្រូវលើការចងក្រងជាឯកសារ និងថែរក្សាឯកសារនៃបណ្ដឹងទាំងអស់ដែលស្ថិតក្នុងចំណាត់ការ។ ប្រសិនបើក្រោយរយៈពេល 15ថ្ងៃ គ្រួសារដែលដាក់ពាក្យបណ្ដឹងមិនបានទទួលព័ត៌មានពីអាជ្ញាធរភូមិ ឬអាជ្ញាធរឃុំ ឬប្រសិនបើគ្រួសាររងការប៉ះពាល់មិនពេញចិត្តចំពោះការសម្រេចធ្វើឡើងនៅក្នុងដំណាក់កាលដំបូង ពួកគេបន្តបណ្ដឹងនោះទៅការិយាល័យស្រុកជាលាយលក្ខអក្សរ ឬដោយផ្ទាល់មាត់។ ក្នុងករណីដែលគ្រួសាររងគ្រោះជាជនជាតិដើមភាគតិច ពួកគេអាចរួមដំណើរជាមួយអ្នកសម្របសម្រួលម្នាក់ ដែលជាអ្នកអាចសន្ទនាជាភាសារបស់ជនជាតិដើមនោះ និងមាននាទីជាអ្នកតស៊ូមតិសម្រាប់គ្រួសារដែលដាក់បណ្ដឹងនោះនៅក្នុងដំណើរការនេះ ដែលគម្រោងជាអ្នកចេញថ្លៃ។

*ដំណាក់កាលទីបី - នៅថ្នាក់ស្រុក*

ការិយាល័យស្រុកមានរយៈពេល 15 ថ្ងៃ ដើម្បីដោះស្រាយបណ្ដឹងដើម្បីផ្ដល់ជាទីពេញចិត្តនៃភាគីពាក់ព័ន្ធទាំងអស់។ ប្រសិនបើមិនអាចដោះស្រាយបណ្ដឹងបាននៅក្នុងដំណាក់កាលនេះទេ ការិយាល័យស្រុកនឹងបញ្ជូនករណីនេះទៅ គណៈកម្មការដោះស្រាយបណ្ដឹងថ្នាក់ខេត្ត។ ក្នុងករណីដែលគ្រួសាររងគ្រោះជាជនជាតិដើមភាគតិច ពួកគេអាចរួមដំណើរជាមួយអ្នកសម្របសម្រួលម្នាក់ដែលជាអ្នកអាចសន្ទនាជាភាសារបស់ជនជាតិដើមនោះ និងមាននាទីជាអ្នកតស៊ូមតិសម្រាប់គ្រួសារដែលដាក់បណ្ដឹងនោះនៅក្នុងដំណើរការនេះ ដោយគម្រោងជាអ្នកចេញថ្លៃ ។

*ដំណាក់កាលទៅបួន - គណៈកម្មការដោះស្រាយបណ្ដឹងថ្នាក់ខេត្ត*

គណៈកម្មការដោះស្រាយបណ្ដឹងថ្នាក់ខេត្ត ដែលមានសមាសភាពជា អភិបាល ឬ អភិបាលរងខេត្ត ជាប្រធាន និងប្រធានមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្តជាសមាជិក (ដែលនឹងត្រូវបង្កើតឡើងនៅក្នុងខេត្តនីមួយៗ មុន DMS) ជួបជាមួយភាគីដើមបណ្ដឹង និងព្យាយាមដោះស្រាយបណ្ដឹងនោះ។ គណៈកម្មការនេះក៏អាចស្នើសុំ PRSC-WG ធ្វើការពិនិត្យ DMS ដោយស្ថាប័នតាមដានឯករាជ្យ (EMA)។ ក្នុងរយៈពេល 30 ថ្ងៃ ការដាក់ជូនបណ្ដឹងមកគណៈកម្មការដោះស្រាយទំនាស់ថ្នាក់ខេត្ត ត្រូវធ្វើជាលាយលក្ខអក្សរ និងសេចក្ដីសម្រេចនឹងត្រូវផ្ញើជូន IRC, MRD និង PAH។ ក្នុងករណីដែលគ្រួសាររងគ្រោះជាជនជាតិដើមភាគតិច ពួកគេអាចរួមដំណើរជា

មួយអ្នកសម្របសម្រួលម្នាក់ ដែលជាអាចសន្ទនាជាភាសារបស់ជនជាតិដើមនោះ និងមាននាទីជាអ្នកតស៊ូមតិសម្រាប់គ្រួសារដែលដាក់បណ្ដឹងនោះនៅក្នុងដំណើរការនេះ ដែលគម្រោងជាអ្នកចេញថ្លៃ។

*ដំណាក់កាលចុងក្រោយ - តុលាការ*

ប្រសិនបើគ្រួសាររងការប៉ះពាល់ មិនសុខចិត្តចំពោះដំណោះស្រាយដែលបានស្នើឡើងដោយគណៈកម្មការដោះស្រាយទំនាស់ថ្នាក់ខេត្ត ដោយផ្អែកលើគោលនយោបាយដែលបានឯកភាពគ្នានៅក្នុង RPF-RP គណៈកម្មការនេះត្រូវរៀបចំនីតិវិធីរដ្ឋបាលតបនឹងគ្រួសាររងការប៉ះពាល់ ដោយមានការចូលរួមពីព្រះរាជអាជ្ញានៅថ្នាក់ខេត្ត។ ករណីបណ្ដឹងនេះនឹងត្រូវដាក់ជូនតុលាការខេត្ត បណ្ដឹងនេះនឹងត្រូវដោះស្រាយតាមនីតិវិធីរបស់តុលាការខេត្ត។ ទន្ទឹមនឹងនេះ គ្រួសាររងការប៉ះពាល់អាចដាក់បណ្ដឹងមកតុលាការខេត្តផងដែរ។ នៅក្នុងពេលដោះស្រាយបណ្ដឹងនេះ រាជរដ្ឋាភិបាលនឹងស្នើសុំតុលាការផ្ដល់ការអនុញ្ញាតឲ្យគម្រោងបន្តអនុវត្តដោយគ្មានការរំខាន នៅក្នុងពេលកំពុងដោះស្រាយករណីបណ្ដឹងនេះ។ ប្រសិនបើភាគីណាមួយមិនពេញចិត្តចំពោះការសម្រេចរបស់តុលាការខេត្ត ភាគីនោះអាចដាក់បណ្ដឹងទៅតុលាការជាន់ខ្ពស់ជាងនេះជាបន្ត។ រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តការសម្រេចរបស់តុលាការ។

បន្ថែមលើយន្តការនានាខាងលើ និងតាមលក្ខខណ្ឌរបស់ PAP និង PAHs, បណ្ដឹងសារទុក្ខអាចត្រូវដាក់ជូនទៅអង្គភាពផ្សះផ្សារដទៃទៀត ដូចជា ក្រុមប្រឹក្សាចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃនៅតាមវត្តក្នុងមូលដ្ឋាន ឬ អង្គភាពដោះស្រាយជម្លោះដទៃទៀតដែលចាត់ចែងឡើងដោយ PAP និង PAHs។

## 8.0 ការចាត់ចែងបើកចំហសម្រាប់ IPDP ដែលត្រូវរៀបចំនៅក្រោម IPPF

ក្នុងករណីដែលអនុគម្រោងទំនងជាបង្កការប៉ះពាល់ដោយផ្ទាល់ ឬ ផ្ដល់ប្រយោជន៍ដល់សហគមន៍ជនជាតិដើមភាគតិច អនុគម្រោងទាំងនោះនឹងពុំបានទទួលការអនុម័តឯកភាពជាចុងក្រោយឡើយ រហូតដល់ពេលដែល SIA-IPDP ត្រូវបានបើកចំហទាំងស្រុង តាមវិធីសមស្រប នៅលំដាប់ថ្នាក់នៃសហគមន៍រងការប៉ះពាល់នោះ។ នេះមានន័យថា ការបើកចំហនឹងត្រូវពិភាក្សា នៅក្នុងដំណើរការពិគ្រោះយោបល់ដោយសេរី ជាមុន ប៉ុន្តែអាចពាក់ព័ន្ធនឹងការថតចម្លងលើក្រដាសនូវឯកសារនានាដែលមានជាភាសាក្នុងមូលដ្ឋាន នៅក្នុងទីប្រជុំសាធារណៈ(ដូចជា មណ្ឌលសហគមន៍) ការចែកចាយសេចក្ដីសង្ខេបមួយសន្លឹក(ជាភាសាសមស្រប) នៃឯកសារពាក់ព័ន្ធនៅក្នុងការជួបជុំជាសាធារណៈ ក៏ដូចជា បទបង្ហាញផ្ទាល់មាត់ជាភាសាសមស្រប ដោយទីប្រឹក្សា ដែលត្រូវបានជួលសម្រាប់ការរៀបចំនិងពិគ្រោះយោបល់អំពីឯកសារទាំងនេះ។ នៅពេលដែលឯកសារទាំងនេះត្រូវបានបើកចំហ និងពិភាក្សានៅកម្រិតសហគមន៍រួចរាល់ហើយ ហើយដំណើរការនេះត្រូវបានចងក្រងជាឯកសារនៅក្នុងបរិបទពាក់ព័ន្ធរួចមក ឯកសារទាំងនេះនឹងត្រូវដាក់ជូនសម្រាប់ការពិនិត្យដោយអ្នកឯកទេសសង្គមនៃគម្រោង និងផ្សព្វផ្សាយនៅក្នុងវេបសាយគម្រោង។ ឯកសារទាំងនេះក៏នឹងត្រូវបញ្ជូនមកធនាគារពិភពលោក ដើម្បីពិនិត្យ និងផ្សព្វផ្សាយនៅលើវេបសាយរបស់ធនាគារពិភពលោកផងដែរ។

## 9.0 ថវិកា

| ល.រ | សកម្មភាព | សេចក្ដីអធិប្បាយ | សន្ទស្សន៍ថ្លៃ (ដុល្លារអាមេរិក) |
|---|---|---|---|

| ល.រ | សកម្មភាព | សេចក្តីអធិប្បាយ | សន្ទស្សន៍ថ្លៃ (ដុល្លាអាមេរិក) |
|---|---|---|---|
| 1 | | ការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច ក្នុងខេត្តទាំងប្រាំមួយនៃអនុគម្រោង ក្នុងពេលរៀបចំ ESMP និងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) | 20.000 |
| 2 | | ជួលទីប្រឹក្សាជាតិ (មិនពេញម៉ោង) ដើម្បីរៀបចំ IPDPs និងជំពូកពាក់ព័ន្ធនៃ EMSPs | 30.000 |
| 3 | | ជួលអ្នកសម្របសម្រួលពីរភាសា (តាមការចាំបាច់) ដើម្បីជួយដល់គ្រួសាររងការប៉ះពាល់ជាជនជាតិដើម ក្នុងដំណើរការបណ្តឹងសារទុក្ខ | 5.000 |
| 4 | | ជួលទីប្រឹក្សាជាតិដើម្បីធ្វើការវាយតម្លៃ IPDPs តាមបែបចូលរួម | 10.000 |
| | | **សរុប** | **65.000** |